





# របាយការណ៍សង្ខេប

## វេទិកាថ្នាក់ជាតិលើកទី ១ ស្តីពីមនុស្ស និងព្រៃឈើ

## វិថីឆ្ពោះទៅកាន់ការគ្រប់គ្រងព្រៃឈើ និងការចិញ្ចឹមជីវិត ប្រកបដោយនិរន្តរភាព

ថ្ងៃទី ២៥-២៦ ខែកុម្ភៈ ឆ្នាំ២០១៤ រាជធានីភ្នំពេញ

**វេទិកាថ្នាក់ជាតិលើកទី១ ស្តីពីមនុស្ស និងព្រៃឈើ**
វិថីឆ្ពោះទៅកាន់ការគ្រប់គ្រងព្រៃឈើ និងការចិញ្ចឹមជីវិតប្រកប
ដោយនិរន្តរភាព

©រក្សាសិទ្ធិដោយ RECOFTC ឆ្នាំ ២០១៤
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

រាល់រូបភាពដែលប្រើប្រាស់ក្នុងរបាយការណ៍នេះជាកម្មសិទ្ធិរបស់ RECOFTC

Reproduction of this publication for educational or other non-commercial purposes is authorized without prior written permission from the copyright holders provided the source is fully acknowledged. Reproduction of this publication for resale or other commercial purposes is prohibited without written permission of the copyright holder.

# មាតិកា


សេចក្តីផ្តើម ............ ១
ស្ថានភាពបច្ចុប្បន្នរបស់សហគមន៍ ............ ៣
ការគាំទ្ររបស់រាជរដ្ឋាភិបាលចំពោះសហគមន៍ ............ ៤
- រដ្ឋបាលព្រៃឈើ ............ ៤
- អគ្គនាយកដ្ឋាន រដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ............ ៤
- រដ្ឋបាលជលផល ............ ៥

តួនាទីរបស់ភាគីពាក់ព័ន្ធក្នុងដំណើរការអភិវឌ្ឍសហគមន៍ ............ ៦
- ការចូលរួមរបស់បណ្តាញអង្គការសង្គមស៊ីវិលក្នុងការថែរក្សា គ្រប់គ្រង និងប្រើប្រាស់ធនធានព្រៃឈើនៅកម្ពុជា. ៦
- ការរួមចំណែករបស់គ្រឹះស្ថានឧត្តមសិក្សាក្នុងការគាំទ្រការអភិវឌ្ឍសហគមន៍ ............ ៦
- បទពិសោធន៍ក្នុងការរៀបចំសហគ្រាសអនុផលព្រៃឈើ ............ ៧
- សមាគមន៍ផ្តៅនៅកម្ពុជា ............ ៧
- ការអភិវឌ្ឍសហគមន៍អេកូទេសចរណ៍ចំបក់ប្រកបដោយការទទួលខុសត្រូវ ............ ៧
- ការលើកកម្ពស់របរចិញ្ចឹមជីវិតរបស់សហគមន៍នេសាទ ............ ៨

មេរៀន និងបទពិសោធន៍ក្នុងការគ្រប់គ្រងសហគមន៍ ............ ៩
- ជោគជ័យ និងមេរៀនបទពិសោធន៍ ក្នុងការគ្រប់គ្រងសហគមន៍ ............ ៩
- ការរៀបចំតំបន់អេកូទេសចរណ៍ក្នុងសហគមន៍តំបន់ការពារធម្មជាតិចំបក់ ............ ៩

លទ្ធផលកិច្ចពិភាក្សាស្តីពីបញ្ហា និងការប្រឈម មេរៀនបទពិសោធន៍ និងការអនុវត្តល្អ ............ ១០
ជំហានបន្ទាប់ និងការប្តេជ្ញាចិត្តក្នុងការអភិវឌ្ឍសហគមន៍ ............ ១៦
ការគាំទ្ររបស់ RECOFTC ទៅក្នុង ផែនការសកម្មភាពសហគមន៍ ............ ១៩
ការតាំងបង្ហាញស្នាដៃ និងផលិតផលសហគមន៍ ............ ២០
សេចក្តីអំពាវនាវឲ្យធ្វើសកម្មភាព ............ ២២
សេចក្តីសន្និដ្ឋាន ............ ២៤




# សេចក្តីថ្លែងអំណរគុណ

វេទិកាថ្នាក់ជាតិលើកទី១ ស្តីពីមនុស្ស និងព្រៃឈើ បានរៀបចំឡើងដោយមជ្ឈមណ្ឌលសម្រាប់មនុស្ស និងព្រៃឈើ (RECOFTC) សហការជាមួយរដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល (Learning Institute) វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum on Cambodia) និងអង្គការកម្មវិធីផ្លាស់ប្តូរអនុផលព្រៃឈើ (NTFP-EP) ក្រោមជំនួយឧបត្ថម្ភពី ១) សហភាពអឺរ៉ុប (EU) ២)បណ្តាញសង្គមព្រៃឈើអាស៊ាន (ASFN) ៣) ទីភ្នាក់ងារកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍនៃប្រទេសស្វីស (SDC) និង ៤)មូលនិធិបរិស្ថានសកល តាមរយៈកម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ (UNDP-GEF)។

អង្គការ RECOFTC សូមថ្លែងអំណរគុណដល់អ្នករៀបចំកម្មវិធីទាំងអស់ដែលសមាសភាពដូចជា លោក ឡុង រត្តនៈកុមារ លោក អ៊ុក វិបុល លោក ប៊ុន រ៉ាដា លោក ភោគ ប៊ុនថេត លោក ស្រី ម៉ារ៉ូណា លោក ធឹង ស៊ុរិយ៉ា លោកស្រី ដា លីលី លោក ឃូ អៀងហួត ព្រមទាំងបុគ្គលិកអង្គការ RECOFTC ទាំងអស់ដូចជា លោក អេដវីនប៉ាយ៉័ន លោកស្រី ហ៊ូ កល្យាណ លោក ហេង ដា លោក តុល សុខដា លោក កៅ វុត្ថា លោកស្រី សន ចាន់សី លោក ឆេង ចន្នី លោក ឈ្នាង គីរីរ៉ុធ លោក ស្រី អ៊ូច លក្ស្មី កញ្ញា តាន់ សេងហ៊ាន់ និងកញ្ញា អ៊ឹម សុផាន់ណា។

សូមថ្លែងអំណរគុណយ៉ាងជ្រាវជ្រៅដល់អ្នកចូលទាំងអស់ និងជាពិសេសចំពោះវាគ្មិនទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ចូលរួមចែករំលែកចំណេះដឹង បទពិសោធន៍ និងគំនិតយោបល់ល្អៗក្នុងវេទិកានេះ ។

# សេចក្តីផ្តើម

វេទិកាថ្នាក់ជាតិលើកទី១ ស្តីពី មនុស្ស និងព្រៃឈើ ក្រោមប្រធានបទ "វិថីឆ្ពោះទៅកាន់ការគ្រប់គ្រងព្រៃឈើ និងការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព" មានអ្នកចូលរួមសរុប ១៥២ នាក់ មកពីស្ថាប័នរាជរដ្ឋាភិបាល តំណាងសហគមន៍ព្រៃឈើ សហគមន៍នេសាទ សហគមន៍តំបន់ការពារធម្មជាតិ អង្គការមិនមែនរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន វិស័យឯកជន គ្រឹះស្ថានឧត្តមសិក្សា និងអង្គការផ្តល់ជំនួយ។ វេទិកានេះបាន ផ្តល់ឱកាសដល់អ្នកចូលរួមចែករំលែកនូវសមិទ្ធិផលសម្រេចបាន មេរៀនបទពិសោធ ការអនុវត្តល្អៗ និងភាពប្រឈមនានាសម្រាប់ជាមូលដ្ឋាន ក្នុងការលើកឡើងនូវផែនការសកម្មភាព និងគំនិតផ្តួចផ្តើមថ្មីៗក្នុងការអភិវឌ្ឍសហគមន៍ ទាំងបីប្រភេទនៅព្រះរាជាណាចក្រកម្ពុជា។ វេទិកានេះ បានផ្តល់ឱកាសឲ្យភាគីពាក់ព័ន្ធ បង្ហាញពីការប្តេជ្ញាចិត្តក្នុងការបន្តគាំទ្រផែនការ សកម្មភាព និងគំនិតផ្តួចផ្តើមថ្មីៗក្នុងការអភិវឌ្ឍសហគមន៍។

គោលបំណងរបស់វេទិកាថ្នាក់ជាតិលើកទី១ ស្តីពីមនុស្ស និងព្រៃឈើ រួមមាន៖

- ផ្តល់វេទិកាដល់អ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីវាយតម្លៃលើវឌ្ឍនភាពនៃសហគមន៍ព្រៃឈើ ធ្វើការពិភាក្សាអំពី ការប្រឈម រៀបចំផែនការសកម្មភាព និងការច្នៃប្រឌិត សម្រាប់អនាគត និងបង្កើនការប្តេជ្ញាចិត្តក្នុងការពង្រឹង ការគ្រប់គ្រងសហគមន៍ព្រៃឈើ និងការបង្កើនរបរចិញ្ចឹមជីវិតរបស់សហគមន៍នៅកម្ពុជា
- ចែករំលែកនូវបទពិសោធន៍ និងការអនុវត្តល្អៗ
- បង្កើននូវកិច្ចខិតខំប្រឹងប្រែងរួមគ្នា និងសុខដុមនីយកម្មនៃគំនិតផ្តួចផ្តើមថ្មីៗ នាពេលបច្ចុប្បន្ន និងអនាគត។

ឯកឧត្តម ជា សំអាង អនុប្រធានរដ្ឋបាលព្រៃឈើ តំណាងឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ ដែលចូលរួមជាកិត្តិយសក្នុងពេលបើកម្មវិធី បានមានប្រសាសន៍ថា "ការគ្រប់គ្រង និងអភិរក្សព្រៃឈើមាននិរន្តរភាពទៅបានលុះត្រាណាតែមានការចូលរួមពីអ្នកពាក់ព័ន្ធនានា ពិសេសសហគមន៍ទាំងបីប្រភេទ រួមមានសហគមន៍ព្រៃឈើ សហគមន៍នេសាទ និងសហគមន៍តំបន់ការពារធម្មជាតិ" ។ វេទិកានេះ នឹងផ្តល់ឱកាសដល់ស្ថាប័ន និងអ្នកពាក់ព័ន្ធទាំងអស់បង្ហាញពីការប្តេជ្ញាចិត្ត ការគាំទ្រ និងការផ្តួចផ្តើម គំនិតថ្មីក្នុងការអភិវឌ្ឍសហគមន៍ការគ្រប់គ្រងធនធានធម្មជាតិជាពិសេសស្វែងរកយុទ្ធសាស្ត្រក្នុងការគាំទ្រដល់ការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា។

ក្នុងឱកាសនោះដែរ លោក អេដវិន ប៉ាយ័ន អ្នកសម្របសម្រួលកម្មវិធីប្រចាំប្រទេសកម្ពុជា នៃអង្គការ RECOFTC បានថ្លែងនូវចំណាប់អារម្មណ៍រួមទៅលើដំណើរការនៃការរៀបចំវេទិកានេះដោយបញ្ជាក់ថា "នេះគឺជាវេទិកាទីមួយដែលមានការជួប រវាងអ្នកពាក់ព័ន្ធដែលអនុវត្តសហគមន៍ទាំងបីប្រភេទ និងជាសេចក្តីអំពាវនាវដែលបានលើកឡើងនៅវេទិកាថ្នាក់តំបន់លើកទី៣ នៅប្រទេស ក្នុងការជម្រុញ និងអំពាវនាវឲ្យមានការចូលរួមទូលំទូលាយរបស់អ្នកពាក់ព័ន្ធនានានៅតាមបណ្តាប្រទេសទាំង ៦ រួមមាន ព្រះរាជាណាចក្រកម្ពុជា ព្រះរាជាណាចក្រថៃ ឥណ្ឌូនេស៊ី មីយ៉ាន់ម៉ា វៀតណាម និងសាធារណៈរដ្ឋប្រជាមានិតឡាវ ក្នុងការផ្តួចផ្តើមរៀបចំផែនការ និងចាត់អាទិភាពសកម្មភាពក្នុងការអភិវឌ្ឍសហគមន៍ព្រៃឈើនៅក្នុងប្រទេសរបស់ខ្លួន ។

ជាមួយគ្នានេះ លោក Koen Everaert សហប្រធានក្រុមការងារបច្ចេកទេសកំណែទម្រង់វិស័យព្រៃឈើ និងជាប្រតិភូសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា ទទួលបន្ទុកផ្នែកគ្រប់គ្រងធនធានធម្មជាតិ និងការប្រែប្រួលអាកាសធាតុបានលើកឡើងថាដើម្បីសម្រេចបានក្នុងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព គឺផ្តើមចេញពីការផ្តល់អោយប្រជាជនមូលដ្ឋាន នូវឱកាសចូលរួមគ្រប់គ្រងសហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍នេសាទ ព្រមទាំងសិទ្ធក្នុងការសម្រេចចិត្ត និងការគ្រប់គ្រងព្រៃឈើដែលចាំបាច់ត្រូវបង្កើតផែនការគ្រប់គ្រងព្រៃសហគមន៍ បន្ទាប់ពីសហគមន៍ទទួលបានកិច្ចព្រមព្រៀង។ លោកក៏បានលើកឡើងដោយសង្កត់ធ្ងន់ទៅលើបញ្ហាប្រឈមមួយចំនួន ដែលប្រទេសកម្ពុជាកំពុងជួបប្រទះក្នុងការអភិវឌ្ឍសហគមន៍ ដូចជាភាពយឺតយ៉ាវនៃដំណើរកាបង្កើតសហគមន៍ព្រៃឈើការទន្ទ្រានកាប់កាន់ដី និងការអនុម័តផ្តល់ព្រៃរេចរឹលដែលមានតំលៃសេដ្ឋកិច្ចទាបដល់ប្រជាសហគមន៍។ជាពិសេសការធ្វើយ៉ាងណាដើម្បីអោយមានការយកចិត្តទុកដាក់ក្នុងការអនុវត្តល្អៗដែលអាចជួយជម្រុញ ដល់ការគ្រប់គ្រងព្រៃឈើ ដើម្បីទទួលបាននូវសេវាកម្មធម្មជាតិនានាព្រមទាំងផលអនុផលព្រៃឈើ ដែលប្រការនេះអាចរួមចំណែកដល់ការរក្សាលំនឹងបរិស្ថាន ការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងបង្កើនសេដ្ឋកិច្ចនៃប្រទេសកម្ពុជាទាំងមូល។

ទន្ទឹមនឹងនេះ លោកស្រី កាំង ឃីម អនុប្រធានរដ្ឋបាលជលផល បានលើកឡើងពីភាពពាក់ព័ន្ធនៃវិស័យជលផល និងព្រៃឈើ ដោយផ្តោតសំខាន់លើកំណែទម្រង់ស៊ីជម្រៅ តាមរយៈការលុបឡូត៍នេសាទចំនួន ០២ លើក (ឆ្នាំ២០០០ និងឆ្នាំ២០១២) ដោយប្រគល់

ឲ្យសហគមន៍ជាអ្នកគ្រប់គ្រង ក្នុងនោះក៏មានព្រៃលិចទឹក និងព្រៃកោងកាងដែរ។  លោកស្រី បានលើកឡើងនូវទស្សនៈស្រដៀងគ្នាទាក់ទងនឹងតួនាទីដ៏សំខាន់របស់សហគមន៍ ក្នុងការគ្រប់គ្រងធនធានធម្មជាតិ។ បន្ថែមលើនេះ លោកស្រីបាន បញ្ជាក់អំពីចំណុចខ្វះខាតទាក់ទងនឹងការអនុវត្តផែនការគ្រប់គ្រងដែលនៅមានកម្រិត ដោយសារកង្វះធនធានថវិកា  និងធនធានមនុស្ស  ដែលធ្វើឲ្យសហគមន៍មិនអាចអនុវត្តសកម្មភាពរបស់ខ្លួនបានពេញលេញ។

វេទិកាថ្នាក់ជាតិនេះធ្វើឡើងបន្តពីវេទិកាថ្នាក់តំបន់លើកទី៣ ស្តីពីមនុស្ស និងព្រៃឈើ ដែលបានប្រារព្ធធ្វើឡើងនៅថ្ងៃទី ១៩ និង២០ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃ ដែលប្រតិភូនៃប្រទេសកម្ពុជារួមមានតំណាងស្ថាប័នរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលចូលរួមផងដែរ។  អ្នកចូលរួមទាំងអស់មកពីប្រទេសកម្ពុជាបានធ្វើការប្តេជ្ញាចិត្តសម្រាប់រយៈពេលបីឆ្នាំខាងមុខ ដូចជា៖

- ការពិនិត្យឡើងវិញ និងធ្វើការសម្រេចចុងក្រោយទៅលើសៀវភៅណែនាំស្តីពី ការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍
- បង្កើតសហគមន៍ព្រៃឈើ និងធានាដល់ការទទួលស្គាល់សហគមន៍ព្រៃឈើពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បន្តធ្វើការសាកល្បង និងបង្ហាញពីភាពជោគជ័យនៃការគ្រប់គ្រងសហគមន៍ព្រៃឈើ។





# ស្ថានភាពបច្ចុប្បន្នរបស់សហគមន៍

សហគមន៍ព្រៃឈើនៅក្នុងប្រទេសកម្ពុជាមានវឌ្ឍនភាពគួឲ្យកត់សម្គាល់នៅកំលុងពីរទសវត្សរ៍ចុងក្រោយនេះ តាមរយៈការបង្កើនឲ្យមានគោលនយោបាយច្បាស់លាស់ លិខិតបទដ្ឋានគតិយុទ្ធនានា និងការពង្រឹងស្ថាប័នមូលដ្ឋាន។ រាជរដ្ឋាភិបាលកម្ពុជាបានប្ដេជ្ញាចិត្តក្នុងការបង្កើនព្រៃសហគមន៍ឲ្យបាន ០២ លានហិកតានៅត្រឹមឆ្នាំ ២០២៩។ គិតមកត្រឹមឆ្នាំ ២០១៣ មានសហគមន៍ព្រៃឈើសរុបចំនួន ៤៥៧ កន្លែងដែលគ្របដណ្ដប់លើផ្ទៃដីព្រៃឈើជាង ៤០០.០០០ ហិកតា។ ការបង្កើនល្បឿននៃដំណើរការរៀបចំផែនការគ្រប់គ្រងព្រៃសហគមន៍ មានសារៈសំខាន់ក្នុងការសម្រេចបានជោគជ័យរយៈពេលវែងចំពោះសហគមន៍ព្រៃឈើនៅក្នុងប្រទេសកម្ពុជា។ ប៉ុន្តែគិតមកដល់ពេលនេះមានផែនការ គ្រប់គ្រងព្រៃសហគមន៍ តែមួយប៉ុណ្ណោះដែលត្រូវបានអនុម័ត និងផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន ២០ ផ្សេងទៀតកំពុងរង់ចាំការអនុម័ត ។

ចំណែកឯសហគមន៍តំបន់ការពារធម្មជាតិបានចាប់ផ្ដើមបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៥ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន។ មកដល់ឆ្នាំ២០១៣ មានសហគមន៍តំបន់ការពារធម្មជាតិចំនួន ១២១ ត្រូវបានបង្កើតឡើងដែលគ្រប់ដណ្ដប់លើផ្ទៃដីចំនួន ១៦៦.២៩៣ហិកតា។ សហគមន៍ចំនួន ០៧ មានផែនការគ្រប់គ្រង និង ១៤ ផ្សេងទៀតកំពុងដំណើរការរៀបចំផែនការគ្រប់គ្រងរបស់ខ្លួន។ ក្នុងនោះដែរក៏មានសហគមន៍ចំនួន ០៨ បានកំពុងធ្វើសកម្មភាពប្រកបប្រាក់ចំណូលរបស់ខ្លួនតាមរយៈការផ្ដល់សេវាទេសចរណ៍ធម្មជាតិ។

ទន្ទឹមនឹងនេះដែរ សហគមន៍នេសាទក៏មានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ ដែលមកដល់ពេលនេះមានចំនួន ៥១៦ សហគមន៍ (សហគមន៍នេសាទទឹកសាបចំនួន ៤៧៧ និងតំបន់ឆ្នេរចំនួន ៣៩) ក្នុងនោះសហគមន៍ចំនួន ៣២៨ បានចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលគ្របដណ្ដប់លើផ្ទៃដី ៧១៥.៦៤៥ ហិកតា។

# ការគាំទ្ររបស់រាជរដ្ឋាភិបាលចំពោះសហគមន៍

វេទិកាថ្នាក់ជាតិនេះប្រព្រឹត្តទៅរយៈពេល ០២ ថ្ងៃនេះ ដោយមានការចូលរួមធ្វើបទបង្ហាញចំនួន ១២ ផ្សេងៗគ្នាមកពីស្ថាប័នរាជរដ្ឋាភិបាល (តំណាងមកពីរដ្ឋបាលព្រៃឈើ និង រដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនិងអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន) សហគមន៍ (តំណាងសហគមន៍ព្រៃឈើ សហគមន៍នេសាទនិងសហគមន៍តំបន់ការពារធម្មជាតិ) និងភាគីពាក់ព័ន្ធផ្សេងៗដែលរួមមានអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ គ្រឹះស្ថានឧត្តមសិក្សា និងវិស័យឯកជន។

## រដ្ឋបាលព្រៃឈើ



លោក ឡុង រត្តនៈកុមារ អនុប្រធាននាយកដ្ឋានព្រៃឈើ និងសហគមន៍ព្រៃឈើ នៃរដ្ឋបាលព្រៃឈើបានបញ្ជាក់អោយដឹងថា ធនធានព្រៃឈើនៅកម្ពុជា មានការប្រឈមមុខនឹងភាពរេចរឹល ហេតុនេះហើយ ការបង្កើតជាសហគមន៍ព្រៃឈើ មានសារៈសំខាន់ក្នុងការការពារ និងគ្រប់គ្រងធនធានធម្មជាតិ។ ហេតុដូចនេះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដាក់ចេញនូវគោលនយោបាយ និងលិខិតបទដ្ឋានច្បាប់ មួយចំនួនដើម្បីជម្រុញការងារនេះ ដូចជា ច្បាប់ស្តីពីព្រៃឈើ លិខិតបទដ្ឋានច្បាប់ទាក់ទងនឹងសហគមន៍ព្រៃឈើនៅកម្ពុជា កម្មវិធីព្រៃឈើជាតិ ព្រមទាំងការបង្កើតឱ្យមានក្រុមការងារបច្ចេកទេសស្តីពីកំណែទម្រង់ព្រៃឈើជាដើម។

មកដល់ពេលនេះមានផែនការគ្រប់គ្រងព្រៃសហគមន៍តែមួយប៉ុណ្ណោះដែលត្រូវបានអនុម័ត។ លោក ឡុង រត្តនៈកុមារក៏បានទទួលស្គាល់ពីភាពយឺតយ៉ាវនេះដែរ ដោយលោកបានភ្ជាប់ទៅនឹង បញ្ហាកង្វះខាតមន្ត្រីជំនាញក្នុងការពិនិត្យមើលលើសេចក្តីព្រាងផែនការគ្រប់គ្រងព្រៃសហគមន៍ មុននឹងអនុម័ត។ ក្រៅពីនេះក៏មានភាពប្រឈមនានាក្នុងការអនុវត្តសហគមន៍ព្រៃឈើដូចជា បញ្ហាទាក់ទងទៅនឹងភាពយឺតយ៉ាវលើដំណើរការនៃការអនុម័តតំបន់សក្តានុពលពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនិងកង្វះខាត មន្ត្រីជំនាញបច្ចេកទេស។ លោកបានបញ្ជាក់ថា ការងារចាំបាច់ដែលត្រូវតែរៀបចំពេលនេះ គឺការរៀបចំសៀវភៅណែនាំអំពីការរៀបចំផែនការ គ្រប់គ្រង និងយន្តការសម្របសម្រួលដើម្បីគៀងគរធនធានក្នុងការជួយគាំទ្រលើការអភិវឌ្ឍសហគមន៍ អោយមានប្រសិទ្ធិភាព ។

## អគ្គនាយកដ្ឋាន រដ្ឋបាលការពារ និងអភិរក្សធម្មជាតិ



លោក កែន សេរីរដ្ឋា អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថានបានលើកឡើងក្នុងបទបង្ហាញថា សហគមន៍តំបន់ការពារធម្មជាតិបានចាប់ផ្តើមបង្កើតចាប់តាំងពី ឆ្នាំ១៩៩៥។ មានប្រជាសហគមន៍រាប់ពាន់គ្រួសាររស់នៅដោយពឹងអាស្រ័យលើធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ ។ ទោះជាយ៉ាងណាការបង្កើតប្រព័ន្ធតំបន់ការពារធម្មជាតិបានដាក់សំពាធ ដល់ប្រជាពលរដ្ឋដែលបាននិង កំពុងរស់នៅ និងប្រើប្រាស់ធនធានធម្មជាតិពីតំបន់ការពារធម្មជាតិទាំងនោះ។ ជាមួយគ្នានេះដែរ តំបន់ព្រៃឈើដែលបានប្រគល់ឲ្យសហគមន៍គ្រប់គ្រងភាគច្រើន

ជាតំបន់ ដែលពុំសូវមានតម្លៃសេដ្ឋកិច្ចខ្ពស់ ដែលមិនអាចឆ្លើយតបនឹងតម្រូវការរបស់សហគមន៍ក្នុងការទ្រទ្រង់ជីវភាពរស់នៅឡើយ ។ លោកក៏បានលើកឡើងផងដែរពីភាពប្រឈមនានាដែលទាក់ទងទៅនឹងគោលនយោបាយ អភិបាលកិច្ច និងវិមជ្ឈការ សម្ពាធនៃគម្រោងវិនិយោគនានា កង្វះខាតនូវយន្តការនៃការគ្រប់គ្រងទំនាស់ ការចែកចាយព័ត៌មាន និងចំណេះដឹង ក៏ដូចជាកង្វះខាតនូវប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃ។ ជាពិសេស ការបែងចែកផលប្រយោជន៍ សិទ្ធិ និងកម្មសិទ្ធិដីធ្លី និងធនធាន ដែលប្រការនេះទាក់ទងផងដែរទៅនឹងនិរន្តរភាពនៃការចិញ្ចឹមជីវិតរបស់ប្រជាសហគមន៍។

ដើម្បីដោះស្រាយនូវភាពប្រឈមខាងលើ លោកបានលើកឡើងនូវគំនិតផ្តួចផ្តើមមួយចំនួនដូចជា ការឆ្លើយតបទៅនឹងកំណើននៃតម្រូវការសម្រាប់សហគមន៍តំបន់ការពារធម្មជាតិដែលតម្រូវអោយធ្វើការពិនិត្យ និងកែសម្រួល គោលនយោបាយ ក្របខ័ណ្ឌច្បាប់នានា ការកសាងសមត្ថភាព ការរៀបចំស្ថាប័ន ការទំនាក់ទំនងជាដើម ។ ទាក់ទងនឹងការកំណត់អំពីជោគជ័យ ឬប្រសិទ្ធិភាព ឬឥទ្ធិពលនៃការអនុវត្តសហគមន៍តំបន់ការពារធម្មជាតិ (ដែលចាំបាច់ត្រូវរៀបចំ គោលការណ៍ លក្ខណៈវិនិច្ឆ័យ និងសូចនាករ) ការពង្រឹងនូវតួនាទី និងទំនាក់ទំនងរវាងអ្នកពាក់ព័ន្ធ ដូចជាប្រជាសហគមន៍ អាជ្ញាធរមូលដ្ឋាន ក្រុមប្រឹក្សាឃុំ ស្ថាប័នជំនាញ អង្គការសង្គមស៊ីវិល និងគម្រោងអភិវឌ្ឍន៍នានាដើម្បីបង្កើននូវប្រសិទ្ធិភាពនៃការគ្រប់គ្រង ជាពិសេសការរៀបចំយន្តការដោះស្រាយទំនាស់ សិទ្ធិ និងកម្មសិទ្ធិដីធ្លី និងធនធាន ក៏ដូចជាការធ្វើយ៉ាងណាដើម្បីអោយ សហគមន៍តំបន់ការពារធម្មជាតិអាចរួមចំណែកដល់ការធ្វើអោយមាននិរន្តរភាពនៃការចិញ្ចឹមជីវិតរបស់ប្រជាសហគមន៍។

## រដ្ឋបាលជលផល

លោក ពេជ ប៊ុនណា អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ នៃរដ្ឋបាលជលផលបានលើកឡើងថា ទស្សនទាននៃការបង្កើត សហគមន៍នេសាទ មានចាប់តាំងពីឆ្នាំ ១៩៩៨ មកម្ល៉េះ ក្រោមកិច្ចផ្តួចផ្តើមដោយអង្គការមិនមែនរដ្ឋាភិបាល។ សហគមន៍នេសាទគ្របដណ្តប់តំបន់ព្រៃលិចទឹក និងព្រៃកោងកាងដែលគឺជាជម្រកត្រី ហើយក៏ជាតំបន់ទាក់ទាញភ្ញៀវទេសចរណ៍ផងដែរ ដូចនេះការអភិរក្សព្រៃលិចទឹក និងព្រៃកោងកាងមានសារៈសំខាន់ខ្លាំងណាស់ក្នុងការលើកកម្ពស់ជីវភាពប្រជាសហគមន៍ តាមរយៈការនេសាទ និងចំណូលពីទេសចរណ៍។ ក្នុងការអនុវត្តសហគមន៍នេសាទក៏មិនខុសពីសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិដែរ គឺបានជួបប្រទះនូវបញ្ហានានាទាក់ទងទៅនឹងគោលនយោបាយ អភិបាលកិច្ច កិច្ចសហការ និងតម្រូវការក្នុងការគាំទ្រដល់ការចិញ្ចឹមជីវិតរបស់ប្រជានេសាទ ដែលនេះជាភាពប្រឈមដែលរដ្ឋបាលជលផលជួបប្រទះ និងកំពុងខិតខំប្រឹងប្រែងដើម្បីកែសម្រួលអនុក្រឹត្យ និងគោលនយោបាយនានាដែលគាំទ្រដល់ដំណើរការនៃការគ្រប់គ្រងធនធាននេសាទ។ រដ្ឋបាលជលផលបានចូលរួមបង្កើតកន្លែងអភិរក្សសហគមន៍នេសាទបានចំនួន ៣៥៨ កន្លែង បានការពារបង្កើតកន្លែងអភិរក្សព្រៃលិចទឹក ដាំព្រៃលិចទឹក និងអភិរក្សត្រីមេពូជសហគមន៍ផងដែរ ។



# តួនាទីរបស់ភាគីពាក់ព័ន្ធក្នុងដំណើរការអភិវឌ្ឍសហគមន៍

## ការចូលរួមរបស់បណ្តាញអង្គការសង្គមស៊ីវិលក្នុងការថែរក្សា គ្រប់គ្រង និងប្រើប្រាស់ធនធានព្រៃឈើនៅកម្ពុជា

លោក ផាន់ ស៊ីថាន អ្នកគ្រប់គ្រងកម្មវិធីដីធ្លី និងជីវភាព នៃវេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (The NGO Forum on Cambodia) បានបង្ហាញអំពីតួនាទីដ៏សំខាន់ របស់បណ្តាញក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានព្រៃឈើនៅក្នុងប្រទេសកម្ពុជា ដែលក្នុងនោះ លោកបានលើកឡើងនូវបណ្តាញចំនួន ០២ គឺបណ្តាញជនជាតិដើមភាគតិច និងព្រៃឈើ និងបណ្តាញសង្គមស៊ីវិលរេដបូកកម្ពុជា។ នៅថ្នាក់ជាតិ បណ្តាញនេះធ្វើការងារសម្របសម្រួលជាមួយភាគីអ្នកពាក់ព័ន្ធ និងពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងច្បាប់ និងគោលនយោបាយនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងបានពង្រីកការងារលើការដោះស្រាយឥទ្ធិពលអវិជ្ជមាននៃការផ្តល់សម្បទានដីសេដ្ឋកិច្ច សិទ្ធិប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិរបស់ប្រជាជននៅតាមមូលដ្ឋានជាពិសេសជនជាតិដើមភាគតិច។ ដោយឡែកបណ្តាញសង្គមស៊ីវិលរេដបូកកម្ពុជា បង្កើតឡើងក្នុងគោលបំណងដើម្បីចូលរួមអនុវត្ត ផែនទីបង្ហាញផ្លូវរេដបូកកម្ពុជា និងចូលរួមបង្កើតផែនការយុទ្ធសាស្រ្តរេដបូកថ្នាក់ជាតិដើម្បីជំរុញការអនុវត្តរេដបូក ឲ្យមានអភិបាលកិច្ចល្អ និងតម្លាភាព។ ក្នុងដំណើរការអនុវត្តការងារបណ្តាញទាំងពីរបានជួបប្រទះបញ្ហាប្រឈម និងបទពិសោធន៍ដូចជា៖

- ការរឹតបណ្តឹងក្នុងការអនុវត្តសកម្មភាព ជាពិសេសក្នុងកំឡុងពេលបោះឆ្នោត
- អាជ្ញាធរមួយចំនួន បានចាត់ទុកអង្គការសង្គមស៊ីវិល និងសមាជិកបណ្តាញថាមាននិន្នាការគាំទ្រគណៈបក្សនយោបាយ
- ថវិកាគាំទ្រវិស័យព្រៃឈើ ធ្លាក់ចុះ ដោយសារដៃគូអភិវឌ្ឍន៍មួយចំនួនបង្វែរទិសដៅទៅប្រទេសផ្សេងៗ
- ការយល់ដឹងរបស់សមាជិកបណ្តាញអំពីយន្តការរេដបូកនៅមានកម្រិត
- ថវិកាជំនួយលើការគាំទ្រសកម្មភាពនៃកម្មវិធី/យន្តការរេដបូក នៅថ្នាក់មូលដ្ឋានមានកំណត់
- កិច្ចពិភាក្សានៅថ្នាក់ក្រោមជាតិ ទៅលើយន្តការរេដបូកនេះនៅមានកម្រិត
- មន្រ្តីរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ សង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូលដ្ឋានមានការយល់ដឹងមិនទាន់បាន ទូលំទូលាយពីទស្សនៈទានរេដបូក សេរីភាពការទទួលបានព័ត៌មានជាមុន និងការយល់ព្រម ការបែងចែកផលប្រយោជន៍ គោលការណ៍ការពារសង្គម និង បរិស្ថានក្នុងបរិបទរេដបូក ការផ្ទៀងផ្ទាត់ វាយតម្លៃ និងរបាយការណ៍។

## ការរួមចំណែករបស់គ្រឹះស្ថានឧត្តមសិក្សាក្នុងការគាំទ្រការអភិវឌ្ឍសហគមន៍

សាស្រ្តាចារ្យ វេន មុនិន្ទ ព្រឹទ្ធបុរសមហាវិទ្យាល័យព្រៃឈើ នៃសកលវិទ្យាល័យភូមិន្ទកសិកម្ម បានលើកឡើងអំពីការដើរតួយ៉ាងសំខាន់របស់ផ្នែកអប់រំនៅកម្រិតឧត្តមសិក្សា ក្នុងការជម្រុញការងារអភិវឌ្ឍរបស់សហគមន៍ទាំងបីប្រភេទ។ និស្សិតអាចទទួលបានចំណេះដឹងទាំងនៅសាកលវិទ្យាល័យតាមរយៈការចែករំលែកចំណេះដឹង និងបទពិសោធន៍ពីសាស្រ្តាចារ្យ អ្នកសិក្សាស្រាវជ្រាវ និងអ្នកជំនាញ និងការសិក្សាស្រាវជ្រាវដោយខ្លួនឯង និងនៅទីវាលតាមរយៈការចុះកម្មសិក្សា ក្នុងគោលបំណងរៀនសូត្របន្ថែមពីសហគមន៍ជាដើម។ លើសពីនេះ សាកលវិទ្យាល័យក៏បានរួមចំណែក រៀបចំវគ្គបណ្តុះបណ្តាលដល់សហគមន៍ និងរៀបចំឲ្យមានកម្មវិធីដាំដើមឈើផងដែរ។ លោកក៏បានលើកឡើងផងដែរនូវការប្រឈមមួយចំនួនដែលស្ថាប័នរបស់លោកបានជួបប្រទះកន្លងមក៖

- មូលដ្ឋានគ្រឹះនៃការយល់ដឹងពីព្រៃឈើរបស់និស្សិតនៅមានកម្រិតទាបនៅឡើយ
- ទីផ្សារការងារមានលក្ខណៈតូចចង្អៀត ដែលនិស្សិតភាគច្រើនមិនសូវចាប់អារម្មណ៍លើមុខជំនាញនេះ
- ការសិក្សាទាមទារការអនុវត្តនៅទីវាល ដែលទាមទារការ ចំណាយពេលវេលា និងថវិកាច្រើន
- ភាសាគន្លឹះដែលប្រើប្រាស់ក្នុងការងារបណ្តុះបណ្តាលពាក់ព័ន្ធច្រើននឹងបញ្ហាសង្គម/វិទ្យាសាស្រ្តសង្គម
- កង្វះខាតទំនាក់ទំនងនៃសាស្រ្តាចារ្យ មន្រ្តីទទួលបន្ទុក និងសហគមន៍ដោយសារមមាញឹកនឹងជីវភាព
- ទស្សនៈ និងការយល់ឃើញទៅលើការសិក្សាមុខវិជ្ជានេះមិនទាន់មានភាពទូលំទូលាយនៅឡើយ ។

# បទពិសោធន៍ក្នុងការការរៀបចំសហគ្រាសអនុផលព្រៃឈើ

លោក យូ អៀងហួត អ្នកសម្របសម្រួលថ្នាក់ជាតិ នៃកម្មវិធីផ្លាស់ប្ដូរអនុផលព្រៃឈើ (NTFP-EP) បានបង្ហាញអំពីបទពិសោធន៍ក្នុងការរៀបចំសហគ្រាសអនុផលព្រៃឈើ ក្នុងសហគមន៍ព្រៃឈើ និងការប្រកបរបរចិញ្ចឹមជីវិតនៅក្នុងសហគមន៍ព្រៃកន្ធោត (ខេត្តកំពត) ក្រាំងអាត់ (ខេត្តព្រះសីហនុ) ក្រង់តេះ និងពូជ្រៃ (ខេត្តមណ្ឌលគិរី) ពោធិ៍ និងប្រមេរ (ខេត្តព្រះវិហារ)ដោយកម្មវិធីផ្លាស់ប្ដូរអនុផលព្រៃឈើ។ នៅតំបន់ទាំងនេះមានគ្រួសារពី ១០%-៨០% ពឹងអាស្រ័យលើអនុផលព្រៃឈើប្រមាណជា ៥០%-៩៥% និងក្នុងនោះ ៥០%-៩០% សម្រាប់លក់។ ប្រជាសហគមន៍អាចរកចំណូលពីអនុផលព្រៃឈើ ប្រមាណពី ៣០០ ទៅ ៣.០០០ដុល្លារក្នុង ១ឆ្នាំដោយអាស្រ័យលើប្រភេទអនុផលព្រៃឈើដែលមាននៅក្នុងតំបន់របស់ពួកគាត់។

ជាទូទៅ ក្រោមការសម្របសម្រួលការងារដោយខណ្ឌរដ្ឋបាលព្រៃឈើ អាជ្ញាធរមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលសហគ្រាសសហគមន៍អនុផលព្រៃឈើ មានគំរូដូចជា: គណកម្មាធិការអនុផលព្រៃឈើ(ផ្ដៅ ឃ្មុំ ជ័រទឹកជាដើម) ក្រុមអ្នកប្រមូលអនុផលព្រៃឈើ ក្រុមអ្នកកែច្នៃអនុផលព្រៃឈើ និងក្រុមអ្នកទិញ អ្នកលក់ និងអ្នកនាំចេញ។

ដំណើរការអនុវត្តការងារសហគ្រាសសហគមន៍អនុផលព្រៃឈើ ក៏បានជួបប្រទះនឹងបញ្ហាប្រឈមចម្បងមួយចំនួនផងដែរដូចជា៖

- សមត្ថភាពរបស់អាជ្ញាធរ ស្ថាប័ន និងសហគមន៍លើការរៀបចំសហគ្រាសនៅមានកម្រិត
- កង្វះខាតជំនាញស្រាវជ្រាវ ឧបករណ៍ និងជំនាញដើម្បីរៀបចំ និងច្នៃប្រឌិតផលិតផល
- កង្វះខាតចំណេះដឹង និងបទពិសោធន៍លើការគ្រប់គ្រងលំហូរផលិតកម្មដើម្បីឆ្លើយតបទៅនឹងតំរូវការ
- កង្វះខាតការយល់ដឹងលើតម្លៃ និងជំនាញចរចារ
- កង្វះខាតការយល់ដឹងលើការប្រើប្រាស់ និងការដកហូតធនធានមិនទាន់កែច្នៃ
- គុណភាព និងការរៀបចំផលិតផលមិនបានឆ្លើយតបទៅនឹងស្តង់ដាលើទីផ្សារ
- ភាពនៅមានកម្រិត ឬ អវត្តមាននៃឧស្សាហកម្មអនុផលព្រៃឈើក្នុងតំបន់។

# សមាគមផ្ដៅកម្ពុជា

លោក លីប ជាង ប្រធានសមាគមផ្ដៅ ក៏បានធ្វើបទបង្ហាញសកម្មភាពអាជីវកម្មរបស់ខ្លួនក្នុងការកែច្នៃផលិតផលផ្ដៅដែលទិញមកពីសហគមន៍ ដែលនេះបានជួយលើកកម្ពស់កម្រិតជីវភាពប្រជាសហគមន៍។ សមាគមទទួលការផ្គត់ផ្គង់ផ្ដៅពីបណ្ដាខេត្តចំនួន ០៧ គឺខេត្តព្រះវិហារ កំពង់ធំ ក្រចេះ កោះកុង កំពង់ស្ពឺ កំពត និងព្រះសីហនុ។ បច្ចុប្បន្ន ការអនុវត្តការងារកែច្នៃផ្ដៅរបស់សមាគមត្រូវប្រឈមនឹងបញ្ហាដូចជា ការដឹកជញ្ជូនថ្លៃថ្លាយ កង្វះការលើកទឹកចិត្តពីរដ្ឋាភិបាល ធនធានផ្ដៅពីព្រៃធម្មជាតិមិនអាចឆ្លើយតបនឹងតម្រូវការទីផ្សារ ការផលិតគ្រឿងសង្ហារឹមធំៗដែលទីផ្សារអន្តរជាតិមិនសូវពេញនិយម និងកង្វះខាតជំនាញក្នុងការកែច្នៃផងដែរ។ ទន្ទឹមនឹងការលើកឡើងនូវដំណោះស្រាយ លោកបានសំណូមពរឲ្យមានការគាំទ្រពីរដ្ឋាភិបាល និងសូមឲ្យមានការសម្របសម្រួលសម្រួលក្នុងការផ្ដល់លិខិតអនុញ្ញាតិលើការដឹកជញ្ជូនឆ្លងកាត់ខេត្ត និងលើកលែងការបង់ថ្លៃសួយសារប្រសិនបើផ្ដៅមកពីសហគមន៍ព្រៃឈើ។

# ការអភិវឌ្ឍសហគមន៍អេកូទេសចរណ៍ចំបក់ប្រកបដោយការទទួលខុសត្រូវ

លោក វ៉ា មឿន នាយកប្រតិបត្តិអង្គការម្លប់បៃតង បានចែករំលែកនូវបទពិសោធន៍ និងភាពជោគជ័យក្នុងការរៀបចំ និងអភិវឌ្ឍន៍សហគមន៍អេកូទេសចរណ៍នៅចំបក់ ដែលបានចូលរួមចំណែកក្នុងការធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតាមរយៈការ ផ្គត់ផ្គង់សេវាកម្ម ទេសចរណ៍ ការបង្កើតអាជីវកម្មខ្នាតតូច ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាការងារគ្រប់គ្រងធនធានធម្មជាតិ (ការលុបបំបាត់ឡបង និងការកាត់បន្ថយបទល្មើសព្រៃឈើជាដើម) និងលើកកម្ពស់វិស័យទេសចរណ៍នៅក្នុងប្រទេសកម្ពុជា។

ដើម្បីអនុវត្តរៀបចំសហគមន៍អេកូទេសចរណ៍ និងអនុវត្តការងារប្រកបដោយភាពជោគជ័យចាំបាច់ត្រូវមានគណ:កម្មការគ្រប់គ្រងសហគមន៍ទេសចរណ៍ធម្មជាតិមួយ មានលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រប់គ្រងដែលបានបង្កើតឡើងតាមរយៈវិធីសាស្ត្រមួយដោយ មានការចូលរួម។ ការកសាងសមត្ថភាពសម្រាប់គណៈកម្មការគ្រប់គ្រង និងអ្នកផ្តល់សេវាកម្មទេសចរណ៍ត្រូវបានធ្វើឡើងជាទៀងទាត់ក៏ជាកត្តាចំបាច់ផងដែរ។ លើសពីនេះការចូលរួម និងការទទួលបានផលប្រយោជន៍ដោយសមធម៌ក្នុងចំណោមសមាជិកសហគមន៍

ត្រូវបានគិតគូរយ៉ាងម៉ត់ចត់ក្នុងពេលអនុវត្តគម្រោង។ វិធីសាស្ត្រនេះបានជម្រុញការចូលរួម ការគាំទ្រ និងការសហការពីសមាជិករបស់សហគមន៍ទាំងអស់ ហើយជៀសវាងបាននូវជំលោះផ្ទៃក្នុង។ នៅក្នុងដំណើរការរៀបចំសហគមន៍ និងការអនុវត្តបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចជា៖

- ការសិក្សាអប់រំនៅមានកម្រិតទាបក្នុងចំណោមប្រជាជនក្នុងភូមិ
- ការលំបាកក្នុងការធ្វើឲ្យអ្នកភូមិ សមាជិកគណៈកម្មការគ្រប់គ្រង អាជ្ញាធរមូលដ្ឋាន និងភ្ញៀវទេសចរណ៍ ទទួលយកនូវអភិក្រម និងទំរង់ការដែលបង្កើតថ្មីៗ
- ការកាប់បំផ្លាញ ការរុករានយកដីព្រៃ ការដុតព្រៃ និងការបរបាញ់សត្វនៅក្នុង និងជុំវិញសហគមន៍
- សមាជិកគណៈកម្មការគ្រប់គ្រងសហគមន៍នៅតែពឹងផ្អែកយ៉ាងខ្លាំងទៅលើប្រធានសហគមន៍។

## ការលើកកម្ពស់របរចិញ្ចឹមជីវិតរបស់សហគមន៍នេសាទ

លោក អ៊ុង ទិវា នាយកប្រតិបត្តិអង្គការមរតក បានធ្វើបទបង្ហាញដោយផ្តោតសំខាន់ទៅលើការងារជួយសហគមន៍ក្រីក្រជុំវិញធកកំពង់សោម ឲ្យចេះសហការអនុវត្តគំរោងខ្នាតតូច ដើម្បីរកចំណូលចិញ្ចឹមជីវិតដោយបន្ថយការពឹងអាស្រ័យលើធនធានធម្មជាតិ តាមរយៈរួមគ្នា អភិវឌ្ឍន៍បណ្តាញសេដ្ឋកិច្ច សហគមន៍/សហគ្រិនខ្នាតតូច និងចូលរួមក្នុងការងារអភិបាលកិច្ចថ្នាក់ក្រោមជាតិ ដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងធនធានធម្មជាតិ។ គួរបញ្ជាក់ថា ដោយមើលឃើញនូវការថយចុះនៃធនធានជលផលនៅតំបន់ធកកំពង់សោម សហគមន៍នេសាទតាមឃុំនីមួយៗត្រូវបានបង្កើតឡើងដោយមានការគាំទ្រពីដៃគូអភិវឌ្ឍន៍ អាជ្ញាធរ និងមន្ត្រីជលផលចាប់តាំងពីឆ្នាំ ២០០៣ មក។ ក្រោមការជួយជ្រោមជ្រែងផ្នែកកសាងសមត្ថភាព សហគមន៍នេសាទមានលទ្ធភាពគៀងគរធនធានក្នុងតំបន់ដើម្បីបម្រើដល់កិច្ចការអភិវឌ្ឍន៍សហគមន៍ ហើយពួកគាត់មានទំនុកចិត្តសហការជាមួយមន្ត្រីជលផល អាជ្ញាធរ លើកគម្រោងអភិវឌ្ឍន៍ដើម្បីស្វែងរកប្រយោជន៍ចូលក្នុងសហគមន៍របស់ខ្លួន។ អង្គការមរតក បានបង្កើតក្រុមគ្រប់គ្រងទុនបង្វិលអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍ និងក្រុមចាប់អារម្មណ៍ក្នុងជម្រើសមុខរបរ ផ្សេងគ្នាដែលក្រុមទាំងពីរសហការគ្នា ក្នុងគោលបំណងរួមដើម្បីកាត់បន្ថយសំពាធលើការប្រើប្រាស់ធនធានធម្មជាតិលើសកម្រិត។



# មេរៀន និងបទពិសោធន៍ក្នុងការគ្រប់គ្រងសហគមន៍

## ជោគជ័យ និងមេរៀនបទពិសោធន៍ ក្នុងការគ្រប់គ្រងសហគមន៍

លោក តន ទីន លេខាគណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើត្រពាំងរូង ក្នុងខេត្តកំពង់ធំ បានលើកឡើងក្នុងបទបង្ហាញរបស់លោកថា សហគមន៍របស់លោកគឺជាសហគមន៍ព្រៃឈើដំបូងគេនៅកម្ពុជា ដែលមានផែនការគ្រប់គ្រងដោយទទួលបានការអនុម័តក្នុងឆ្នាំ ២០១២។ សហគមន៍ព្រៃឈើត្រពាំងរូង មានទីតាំងក្នុងភូមិកូនឆ្នោត ភូមិព្រៃទប់ និងភូមិត្រពាំងអារក្ស ឃុំជ័យ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ បង្កើតឡើង នៅឆ្នាំ១៩៩៩ ហើយមកដល់បច្ចុប្បន្ននេះមានសមាជិកចំនួន ៤៥៦ គ្រួសារ។ ការសម្រេចបានផែនការនេះគឺអាស្រ័យដោយមានចូលរួមពីសំណាក់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសការគាំទ្រពីរដ្ឋបាលព្រៃឈើ។ ផែនការគ្រប់គ្រងព្រៃសហគមន៍ត្រូវបានរៀបចំឡើងដោយមានរយៈពេល ១៥ ឆ្នាំ (២០១២-២០២៧) ក្នុងគោលបំណងដើម្បីអភិវឌ្ឍន៍ ប្រើប្រាស់ និងគ្រប់គ្រងធនធានព្រៃសហគមន៍ប្រកបដោយនិរន្តរភាព រួមចំណែកដល់ការបង្កើនសេដ្ឋកិច្ចគ្រួសារ និងសង្គមជាតិ។ ទោះបីជាសហគមន៍ទទួលបានផែនការគ្រប់គ្រងក៏ដោយក្តី ក៏កន្លងមក សហគមន៍បានជួបការលំបាកមួយចំនួនដូចជា ខ្វះជំនាញ និងបច្ចេកទេសក្នុងការរៀបចំថ្នាលបណ្តុះកូនឈើ ខ្វះជំនាញបច្ចេកទេសការធ្វើ សុរុង្គ្គកម្មព្រៃឈើ ខ្វះអ្នកជួយសម្របសម្រួលក្នុងការរៀបចំក្រុមសន្សំ និងខ្វះថវិកាសំរាប់អនុវត្តផែនការនាឆ្នាំបន្ទាប់ជាដើម។

លោកស្រី នង លឹមហ៊ាង ប្រធានសហគមន៍នេសាទឃុំជ្រោយស្វាយ ខេត្តកោះកុងបានលើកឡើងនូវសមិទ្ធិផលនៅក្នុងសហគមន៍មួយចំនួនដែលកើតចេញពីការសហការគ្នាយ៉ាងជិតស្និតរវាង សហគមន៍ អាជ្ញាធរមូលដ្ឋាន ស្ថាប័នជំនាញរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល។ សហគមន៍ បានធ្វើការងារគ្រប់គ្រងធនធានធម្មជាតិ និងអភិរក្ស ដោយរៀបចំតំបន់អភិរក្សចំនួន ០៣ កន្លែងមានផ្ទៃដីសរុបចំនួន ៤៣ហិកតាទុកសម្រាប់ត្រីមេពង បង្កើតជានាគារក្តាម ០១កន្លែង និងដាំកូនកោងកាងចំនួន ០៥ហិកតា។ ទន្ទឹមនឹងភាពជោគជ័យសហគមន៍នេសាទឃុំ ជ្រោយស្វាយ ក៏បានជួបបញ្ហាប្រឈមស្រដៀងគ្នានឹងសហគមន៍ដ៏ទៃទៀតដែរ ដោយក្នុងនោះមានការនេសាទខុសច្បាប់ អំពើ ហឹង្សា រវាងសហគមន៍ និងអ្នកនេសាទប្រើប្រាស់ឧបករណ៍ខ្នាតធំ សមត្ថភាពគ្រប់គ្រងដឹកនាំរបស់គណៈកម្មការនៅមានកម្រិត កង្វះថវិកាសម្រាប់គម្រោងអភិរក្សធនធានជលផល និងអភិវឌ្ឍន៍សេដ្ឋកិច្ច។ បន្ថែមពីនេះ សហគមន៍ មិនទាន់ទទួលបានការចុះបញ្ជីពីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅឡើយ។

## ការរៀបចំតំបន់អេកូទេសចរណ៍ក្នុងសហគមន៍តំបន់ការពារធម្មជាតិចំបក់

លោក គួច ម៉ន ប្រធានគណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិចំបក់ ក្នុងខេត្តកំពង់ស្ពឺ បានចែករំលែកលទ្ធផលការអនុវត្តការងារ និងមេរៀនជាបទពិសោធដែលនាំឲ្យសហគមន៍នេះ ទទួលបានភាពជោគជ័យក្នុងការរៀបចំតំបន់អេកូទេសចរណ៍។ ប្រភពចំណូលបានមកពីទេសចរណ៍ មានសារៈសំខាន់ខ្លាំងណាស់ក្នុងការធានាដល់និរន្តរភាពនៃការគ្រប់គ្រងសហគមន៍ (ចំណូល ៤០% សម្រាប់ការងារអភិរក្ស ២០% សម្រាប់ការងារអភិវឌ្ឍន៍ ២៥% ជួយសមាជិកងាយរងគ្រោះ និង ១៥% សម្រាប់តំកល់ទុកក្នុងសហគមន៍)។ សកម្មភាពទេសចរណ៍នេះក៏បានផ្តល់ចំណូលដោយផ្ទាល់ដល់ប្រជាពលរដ្ឋក្នុងសហគមន៍ផងដែរ ដូចជាតាមរយៈការផ្តល់សេវាកម្មស្នាក់នៅដល់ភ្ញៀវ ទេសចរណ៍ ម្ហូបអាហារ មធ្យោបាយធ្វើដំណើរ (កង់ រទេះគោ គោយន្ត) ការនាំភ្ញៀវ ការលក់ផលិតផលកែច្នៃ និងវត្ថុអនុស្សាវរីយ៍ជាដើម។ លើសពីនេះសហគមន៍ ក៏បានធ្វើការអភិវឌ្ឍន៍ផ្នែកកសិកម្ម ដោយយកចិត្តទុកដាក់លើការផ្គត់ផ្គង់ទឹកប្រើប្រាស់ការបណ្តុះបណ្តាលកសិករគំរូការសាងសង់ទំនប់ទឹក ការផ្តល់ទុនជួយដល់ក្រុមសន្សំរបស់ស្ត្រី និងការធ្វើស្ទូនបន្លែតាមគ្រួសារ។

លោកក៏បានលើកឡើងបន្តថា ជោគជ័យដែលទទួលបានអាស្រ័យទៅលើការគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវ និងមានតម្លាភាពរបស់គណៈកម្មការគ្រប់គ្រងសហគមន៍ ឆន្ទៈក្នុងការចូលរួមរបស់សមាជិក មានកិច្ចសហការល្អជាមួយភាគីពាក់ព័ន្ធជាដើម ។ ទន្ទឹមនឹងនេះ ដែរ សហគមន៍ក៏បានជួបបញ្ហាប្រឈមមួយចំនួនដែរដូចជា បទល្មើសលួចកាប់ឈើ និងភ្លើងឆេះព្រៃជាដើម។



# លទ្ធផលកិច្ចពិភាក្សាស្តីពី បញ្ហា និងការប្រឈម មេរៀនបទពិសោធន៍ និងការអនុវត្តល្អ

អ្នកចូលរួមទាំងអស់បានបែងចែកជាបីក្រុមរួមមាន៖ ១) ស្ថាប័នរាជរដ្ឋាភិបាល ២) សហគមន៍ និង អាជ្ញាធរដែនដី និង ៣) អង្គការ គ្រឹះស្ថានឧត្តមសិក្សា ម្ចាស់ជំនួយ និងវិស័យឯកជន។ កិច្ចពិភាក្សារួមមាន៖

- កិច្ចពិភាក្សាស្តីពីបញ្ហា និងការប្រឈម មរៀនបទពិសោធន៍ ការអនុវត្តល្អ និង
- កិច្ចពិភាក្សាពីជំហានបន្ទាប់ និងការប្តេជ្ញាចិត្តក្នុងការអភិវឌ្ឍសហគមព្រៃឈើនាពេលអនាគត ។

ពេលបញ្ចប់កិច្ចពិភាក្សា អ្នកតំណាងក្រុមនីមួយៗបានឡើងធ្វើបទបង្ហាញស្តីពីលទ្ធផលក្រុម និងផ្តល់ឱកាសឱ្យក្រុមផ្សេងៗទៀត ក្នុងការចោទសួរ និងផ្តល់មតិយោបល់ ឬជាអនុសាសន៍។

# ស្ថាប័នរាជរដ្ឋាភិបាល

សិក្ខាកាមដែលអញ្ជើញមកពីស្ថាប័នរាជរដ្ឋាភិបាលដែលរួមមាន រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានធ្វើការពិភាក្សា និងចែករំលែកនូវលទ្ធផលដូចមានបង្ហាញក្នុងតារាងខាងក្រោមនេះ៖

| | |
|---|---|
| ១-ការប្រឈមនឹងគោលនយោបាយ | • អនុក្រឹត្យសហគមន៍នេសាទអនុញ្ញាតឲ្យតែសហគមន៍ធ្វើការនេសាទបានត្រឹមតែលក្ខណៈគ្រួសារប៉ុណ្ណោះ<br>• ការរៀបចំគោលការណ៍គ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិនៅមានភាពយឺតយ៉ាវ<br>• ស្ថាប័នជាន់តួនាទីគ្នាក្នុងការគ្រប់គ្រងធនធានធម្មជាតិ<br>• សហគមន៍នេសាទជួបការលំបាកក្នុងការគាំទ្រពីអាជ្ញាធរដែនដីពាក់ព័ន្ធក្នុងការកំណត់ព្រំប្រទល់ និងផែនទី<br>• ការអនុវត្តគោលនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លី ប៉ះពាល់ដល់ដីព្រៃសហគមន៍ |
| ២-ការប្រឈមនឹងការអនុវត្ត | • សហគមន៍ពុំមានប្រាក់ចំណូលសម្រាប់ប្រើប្រាស់ក្នុងការគ្រប់គ្រង និងអនុវត្តន៍ផែនការគ្រប់គ្រងសហគមន៍<br>• ស្ថាប័នជំនាញខ្វះថវិកា និងធនធានមនុស្សក្នុងដំណើរការសម្របសម្រួលសហគមន៍<br>• ការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនៅមិនទាន់បានទូលំទូលាយ<br>• បញ្ហាទំនាស់មិនទាន់មានយន្តការដោះស្រាយច្បាស់លាស់ និងមានភាពយឺតយ៉ាវ |
| ៣-អនុសាសន៍ និងសំណើសកម្មភាព | • ធ្វើវិសោធនកម្មអនុក្រឹត្យដើម្បីអោយឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង<br>• បង្កើតក្រុមការងាររៀបចំគោលការណ៍<br>• រៀបចំដំណើរការពិគ្រោះយោបល់<br>• ពង្រឹងការអនុវត្ត និងការទទួលខុសត្រូវតាមតួនាទី<br>• ពិនិត្យ និងពិគ្រោះយោបល់ដើម្បីដោះស្រាយរាល់ទំនាស់ជាមុន<br>• ជម្រុញយន្តការដោះស្រាយទៅតាមកម្រិត<br>• ជម្រុញក្រសួងរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ចុះបញ្ជីដីរដ្ឋ (ដីព្រៃសហគមន៍ព្រៃឈើ ដីសហគមន៍នេសាទ និងដីសហគមន៍តំបន់ការពារធម្មជាតិ)<br>• សំណើដល់រាជរដ្ឋាភិបាលដើម្បីផ្តល់ថវិកាសម្រាប់គាំទ្រដល់សកម្មភាពរបស់សហគមន៍<br>• ធ្វើវិសោធនកម្មអនុក្រឹត្យដើម្បីបើកឲ្យគណកម្មការសហគមន៍អាចធ្វើអាជីវកម្មបាន (សហគមន៍នេសាទ)<br>• លើកគម្រោងស្នើថវិកាពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍សហគមន៍<br>• លើកគម្រោងថវិកា សម្ភារៈ និងស្នើសុំការគាំទ្រពីដៃគូអភិវឌ្ឍន៍សម្រាប់អនុវត្តនៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ<br>• ជម្រុញការផ្សព្វផ្សាយតាមរយៈសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល<br>• ពង្រឹងសមត្ថភាពមន្ត្រីជំនាញតាមរយៈការផ្តល់វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សា<br>• ពង្រឹងយន្តការដោះស្រាយទំនាស់ដែលមានស្រាប់ឡើងវិញ |
| ៤-មេរៀនបទពិសោធន៍ និងការអនុវត្តល្អ | • ការលើកស្ទួយជីវភាពរបស់សហគមន៍តាមរយៈសក្តានុពលនៃធនធានក្នុងតំបន់<br>• សហគមន៍រឹងមាំដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋានស្ថាប័នពាក់ព័ន្ធ អង្គការជាតិ និងដៃគូក្នុងការគ្រប់គ្រង<br>• ការចូលរួមគ្រប់គ្រង និងទប់ស្កាត់បទល្មើសពីប្រជាពលរដ្ឋក្នុងសហគមន៍<br>• ការអនុវត្តន៍កសិកម្មចំរុះ និងការជីកអណ្តូងនៅក្នុងសហគមន៍<br>• ការបែងចែកផលប្រយោជន៍ទៅដល់សមាជិកសហគមន៍ប្រកបដោយសមធម៌<br>• សហគមន៍មានការទទួលស្គាល់ជាផ្លូវការពីក្រសួងស្ថាប័នពាក់ព័ន្ធ<br>• សហគមន៍មួយចំនួនមានផែនការគ្រប់គ្រងច្បាស់លាស់<br>• សហគមន៍មានប្រាក់ចំណូលតាមរយៈការបង្កើតឲ្យមាននូវសេវាកម្មអេកូទេសចរណ៍<br>• ប្រជាសហគមន៍មានសាមគ្គីភាពផ្ទៃក្នុង<br>• សហគមន៍បានបង្កើតកន្លែងអភិរក្សត្រី អភិរក្សព្រៃ<br>• ការបង្កើតធនាគារក្ដាមរួមផ្សំដោយការផ្តល់ប្រាក់កម្ចីដោយយកការប្រាក់ជាក្តាមមេពង |
| ៥-តួនាទីរបស់ស្ថាប័នជំនាញដើម្បីជម្រុញការអភិវឌ្ឍន៍សហគមន៍ | • ផ្តល់បច្ចេកទេសក្នុងដំណើរការនៃការរៀបចំគ្រប់គ្រងសហគមន៍<br>• សម្របសម្រួលនិងផ្តល់កិច្ចសហការក្នុងការដោះស្រាយទំនាស់<br>• ស្វែងរកដៃគូដើម្បីជួយដល់ដំណើរការគ្រប់គ្រងសហគមន៍<br>• សម្របសម្រួលឲ្យមានការផ្លាស់ប្តូរបទពិសោធន៍សម្រាប់សហគមន៍ |

# សហគមន៍ និងអាជ្ញាធរដែនដី

សិក្ខាកាមដែលអញ្ជើញមកពីសហគមន៍ព្រៃឈើ (សហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍នេសាទ) និងអាជ្ញាធរមូលដ្ឋាន

| | |
|---|---|
| ១-ការប្រឈមនឹងគោលនយោបាយ | • បទបញ្ញាលេខ ០១ របស់រដ្ឋាភិបាលធ្វើឲ្យសមាជិក និងប្រជាពលរដ្ឋដែលមិនមែនជាសមាជិកចូលកាន់កាប់ទន្ទ្រានដីសហគមន៍ (គោលនយោបាយចាស់ សកម្មភាពថ្មី)<br>• ការទទួលស្គាល់ដំណើរការគាំទ្រលើការអភិវឌ្ឍសហគមន៍ពីជំនាញមានភាពយឺតយ៉ាវ |
| ២-ការប្រឈមនឹងការអនុវត្ត | • ការប្រើឧបករណ៍នេសាទខុសច្បាប់<br>• ការនេសាទអនាធិបតេយ្យនៅក្នុងដែនសហគមន៍ និងតំបន់អភិរក្ស<br>• ការកាប់បំផ្លាញព្រៃលិចទឹក និងឈូសឆាយដីព្រៃធ្វើកសិកម្ម ដុតធ្យូង ភ្លើងឆេះព្រៃលិចទឹកនៅរដូវប្រាំង<br>• ខ្វះថវិកាគាំទ្រលើការចុះល្បាត ការបង្រ្កាបបទល្មើសនេសាទគ្រប់ភេទ និងការការពារតំបន់អភិរក្សត្រីមេពូជ<br>• បទល្មើសកាប់រុករានព្រៃឡង់ និងព្រៃជំនឿរបស់ជនជាតិដើមភាគតិច ខ្វះការចូលរួមបង្រ្កាបពីស្ថាប័នជំនាញ<br>• ការទទួលផលពីធនធានព្រៃឈើមានរយៈពេលយូរ ធ្វើឲ្យការចូលរួមរបស់សមាជិកមានការថយចុះ<br>• សហគមន៍មួយចំនួន និងអាជ្ញាធរមូលដ្ឋានមិនមានកិច្ចសហការល្អ |
| ៣-អនុសាសន៍ និងសំណើសកម្មភាព | • ពង្រឹងកិច្ចសហការជាមួយអាជ្ញាធរ ស្ថាប័នជំនាញ និងប្រជាជន<br>• ជំរុញឲ្យធ្វើនិយ័តកម្មអោយបានគ្រប់សហគមន៍<br>• សហគមន៍ត្រូវប្រជុំផ្សព្វផ្សាយដល់ប្រជាសហគមន៍ទាក់ទងទៅនឹងសារៈប្រយោជន៍នៃការរៀបចំសហគមន៍<br>• សហគមន៍ប្តេជ្ញាចូលប្រជុំប្រចាំខែរបស់ឃុំ<br>• មុននឹងធ្វើអភិវឌ្ឍអ្វីមួយត្រូវមានការពិគ្រោះយោបល់ជាមួយសហគមន៍ជាមុន<br>• សំណើសុំបង្កើតក្រុមការងារត្រួតពិនិត្យការអនុវត្តច្បាប់ និងលក្ខន្តិកៈសហគមន៍<br>• ទំនាក់ទំនងជាមួយស្ថាបន័ពាក់ពន្ធ័ដើម្បីរួមគ្នាធ្វើសកម្មភាពគ្រប់គ្រងដែនសហគមន៍<br>• ជំរុញការធ្វើផែនការគ្រប់គ្រងព្រៃសហគមន៍អោយបានឆាប់<br>• អាជ្ញាធរគ្រប់ជាន់ថ្នាក់មាន ឃុំ ស្រុក និងខេត្ត ត្រូវយកចិត្តទុកដាក់លើប្រជាជនដែលខ្វះដីបង្កបង្កើនផល<br>• ធ្វើការល្បាតព្រៃដោយមានការចូលរួមពីគណៈកម្មការសហគមន៍ និងសមាជិក |
| ៤-មេរៀនបទពិសោធន៍ និងការអនុវត្តល្អ | • ការគៀងគរធនធានពីសហគមន៍ខ្លួនឯងតាមរយៈការលក់អាចម៍ដីយកមកអភិវឌ្ឍតំបន់អេកូទេសចរណ៍<br>• កិច្ចសហការល្អជាមួយអាជ្ញាធរ ស្ថាបន័ជំនាញ និងស្ថាបន័ពាក់ពន្ធ័<br>• សហគមន៍មានការចូលរួមក្នុងការអនុវត្តលក្ខន្តិកៈ ច្បាប់នៅក្នុងសហគមន៍<br>• មានការចូលរួមពីសមាជិកសហគមន៍ និងអាជ្ញាធរ<br>• ចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ<br>• មានលិខិតបទដ្ឋាននានានៅក្នុងការអនុវត្តសហគមន៍ទាំងបីប្រភេទ<br>• ការគ្រប់គ្រងមូលនិធិបានល្អ និងមានការគាំទ្រថវិកាពីអង្គការដៃគូ<br>• មានបណ្តាញសហគមន៍ និងសហគមន៍ចុះល្បាតព្រៃសហគមន៍ទៀងទាត់<br>• មានប្រកាសទទួលស្គាល់ពីក្រសួងតាមរយៈព្រះរាជក្រឹត្យ អនុក្រឹត្យ<br>• មានបណ្តាញសហគមន៍ព្រៃឡង់ ៤ ខេត្ត<br>• បញ្ចូលផែនការសហគមន៍ទៅក្នុងផែនការវិនិយោគឃុំ<br>• ការប្រើប្រាស់ថវិកាសហគមន៍ដោយមានតម្លាភាព<br>• មានការទំនាក់ទំនងល្អ ស្វែងរកដៃគូក្នុងការអភិវឌ្ឍសហគមន៍ |
| ៥-តួនាទីរបស់សហគមន៍ក្នុងការជំរុញសកម្មភាព | • គណៈកម្មការសហគមន៍ត្រូវគ្រោងផែនការសកម្មភាព និងជាតំរូវការរបស់ប្រជាជន<br>• សហគមន៍អាចធ្វើផែនការគ្រប់គ្រងដើម្បីអភិវឌ្ឍដោយមាននិរន្តរភាព<br>• ធ្វើផែនការសកម្មភាពប្រចាំឆ្នាំ និងលើកផែនការដាក់បញ្ចូលទៅក្នុងផែនការវិនិយោគឃុំ<br>• តំណាងសហគមន៍ត្រូវលះបង់ពេលវេលា និងសំភារៈ<br>• គណៈកម្មការសហគមន៍ត្រូវមានការសហការល្អ និងសាមគ្គីជាមួយស្ថាប័នពាក់ព័ន្ធ<br>• សហគមន៍ត្រូវចេះកែច្នៃបង្កើតក្រុមតូចៗដើម្បីរកប្រាក់ចំណូល<br>• គណៈកម្មការសហគមន៍ត្រូវទំនាក់ទំនងអាជ្ញាភូមិ ឃុំ រឺស្ថាប័នពាក់ពន្ធ័ដើម្បីពិនិត្យផែនការ និងការអនុវត្តរបស់សហគមន៍<br>• សហគមន៍ រៀបចំសកម្មភាពចុះល្បាត និងប្រជុំប្រចាំខែ<br>• ចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល<br>• ត្រូវពង្រឹងតួនាទីរបស់គណៈកម្មការអោយបានដឹងពីតួនាទី និងភារៈកិច្ចរបស់ខ្លួនអោយច្បាស់លាស់ |

បានធ្វើការពិភាក្សាគ្នាយ៉ាងសកម្ម ហើយទទួលបានលទ្ធផលដូចមានបង្ហាញក្នុងតារាងខាងក្រោម៖

- សហគមន៍តំបន់ការពារធម្មជាតិព្រែកត្នោតមិនមានការគាំទ្រពីមន្ទីរទេសចរណ៍ក្នុងការរៀបចំសេវាលក់សំបុត្រសំរាប់ភ្ញៀវចូលទស្សនា
- មានស្ថាប័នច្រើនគ្រប់គ្រងការប្រើប្រាស់ដីតែមួយកន្លែង
- បណ្តាញសហគមន៍ មិនមានការទទួលស្គាល់ពីអាជ្ញាធរខេត្ត

---

- សមាជិកសហគមន៍មួយចំនួនមិនអនុវត្តលក្ខន្តិកៈរបស់សហគមន៍
- មានការគាំទ្រពីឈ្មួញ(អ្នករកស៊ីលក់ដី)ឲ្យសមាជិកទុន្រ្ទានដីសហគមន៍
- អាជ្ញាធរមួយចំនួនមិនគាំទ្រ និងលើកទឹកចិត្តដល់សហគមន៍ចូលរួមប្រជុំប្រចាំខែ
- អ្នកខាងក្រៅសហគមន៍បំពានលក្ខន្តិកៈសហគមន៍ដោយប្រមូលផលលើសលប់ក្នុងដែនសហគមន៍នេសាទ ធ្វើឲ្យប៉ះពាល់ដល់ធនធានសហគមន៍
- ការអនុវត្តច្បាប់ទៅលើជនល្មើសពុំទាន់មានប្រសិទ្ធភាពនៅឡើយ
- អាជ្ញាធរមួយចំនួនឃុបឃិតជាមួយអ្នកប្រព្រឹត្តបទល្មើស

---

- រៀបចំកម្មវិធីផ្សព្វផ្សាយច្បាប់ជលផលដល់ប្រជាជន
- ស្នើសុំរដ្ឋាភិបាលកាត់បន្ថយការផ្តល់ដីសម្បទានសេដ្ឋកិច្ច
- សុំជួយបង្វិលដីសហគមន៍ឲ្យត្រូវចំណុចដែលសហគមន៍ចង់ការពារ
- ផ្តល់បច្ចេកទេសរៀបចំថ្នាលបណ្តុះកូនឈើ និងដាំកូនឈើ
- សហគមន៍ត្រូវប្រជុំពង្រឹងការអនុវត្តជាប្រចាំ
- រាល់ផែនការរបស់សហគមន៍ត្រូវបញ្ចូលទៅក្នុងផែនការវិនិយោគឃុំ
- ក្រសួងពាក់ពន្ធ័ និងអង្គការដៃគូជួយពង្រឹងសមត្ថភាពគណៈកម្មការ និងអាជ្ញាធរភូមិ ឃុំ ដើម្បីធ្វើការងាររួមគ្នា
- ជំរុញឲ្យមានការចុះបញ្ជីក្បាលដីស្រែសហគមន៍ជាលក្ខណៈប្រពន្ធ័ដើម្បីទប់ស្កាត់ការរំលោភយកដីព្រៃ សុំបោះបង្គោលព្រំប្រទល់សហគមន៍
- មន្ត្រីពាក់ពន្ធ័ចូលរួមបង្ក្រាបបទល្មើស
- ស្ថាបន័ពាក់ពន្ធ័ដាក់កំរិតទោសទណ្ឌកំរិតធ្ងន់ដល់ជនល្មើស

---

- មានរចនាសម្ព័ន្ធដឹកនាំច្បាស់លាស់ និងមានការចូលរួមយ៉ាងសកម្មពីសមាជិក
- ដោះស្រាយទំនាស់ដោយមានការចូលរួម(អាជ្ញាធរ ក្រុមហ៊ុន និងស្ថាប័នជំនាញ)
- ការគាំទ្រច្បាប់គ្រប់គ្រាន់
- ទទួលបានវគ្គបណ្តុះបណ្តាលមុនពេលចុះអនុវត្តការងារ  ធ្វើឲ្យការអនុវត្តការងារបានល្អ
- បែងចែកតំបន់គ្រប់គ្រងក្នុងព្រៃសហគមន៍ដែលងាយស្រួលគ្រប់គ្រងទៅតាមគោលបំណង
- បានចុះបញ្ជីក្បាលដីសហគមន៍ពីសុរិយោដីជាលក្ខណៈប្រពន្ធ័
- ការផ្សព្វផ្សាយអំពីច្បាប់ព្រៃឈើដល់សហគមន៍បានញឹកញាប់
- ការផ្សព្វផ្សាយអំពីផលប្រយោជន៍នៃព្រៃឈើ អំពីការទទួលផលបានមកពីព្រៃសហគមន៍
- ប្រជាជនមួយចំនួនដែលមានការយល់ដឹងមានការចូលរួមបានល្អ
- គណៈកម្មការគ្រប់គ្រងសហគមន៍ព្រៃឈើមួយចំនួនសកម្មនឹងការងារ
- យកបញ្ហាដែលកើតមានឡើងដាក់លើតុ ដើម្បីពិភាក្សាក្នុងកិច្ចប្រជុំថ្នាក់ឃុំ ស្រុក ខេត្ត និងស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយ
- គណៈកម្មាធិការសហគមន៍ និងសមាជិកមានការលះបង់ខ្ពស់  និងមិនគិតពីផលប្រយោជន៍
- សហគមន៍មិនរង់ចាំផែនការគ្រប់គ្រងទេ គឺសហគមន៍រៀបចំផែនការសកម្មភាពប្រចាំថ្ងៃរបស់ខ្លួន

---

- សហគមន៍ត្រូវមានផែនការសកម្មភាពរបស់ខ្លួន និងចេះដោះស្រាយទំនាស់
- ប្រធានគណៈកម្មការសហគមន៍ត្រូវស្វែងរកដៃគូ និងអ្នកគាំទ្រថវិកាបច្ចេកទេស
- ការប្រើប្រាស់ធនធានអនុផលព្រៃឈើអោយមានសមធម៌នៅក្នុងសហគមន៍ព្រៃឈើ
- ត្រូវអញ្ជើញអាជ្ញាធរអោយចូលរួមប្រជុំពីការងារសហគមន៍ប្រចាំឆ្នាំ
- ការគ្រប់គ្រងថវិកានៅក្នុងសហគមន៍អោយមានតម្លាភាព
- សហគមន៍អាចធ្វើរបាយការណ៍ពីគំរោងអភិវឌ្ឍជូនទៅអាជ្ញាធរ ស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូ
- ក្នុងនាមជាគណៈកម្មការសហគមន៍ត្រូវជំរុញការផ្សព្វផ្សាយ  ការការពារធនធានធម្មជាតិនៅដែនសហគមន៍អោយមាននិរន្តរភាព
- បន្តផ្សព្វផ្សាយដល់សមាជិកអោយមានការយល់ដឹងបន្ថែមអំពីសារប្រយោជន៍ព្រៃសហគមន៍ដើម្បីបង្កើនការចូលរួម
- ដឹកនាំការប្រជុំប្រចាំខែ និងដោះស្រាយបញ្ហានានា
- សហគមន៍ចង់បង្កើតតំបន់ទេសចរនៅក្នុងតំបន់ព្រៃឈើសហគមន៍គ្រប់គ្រង ដើម្បីកាត់បន្ថយអ្នកភូមិចូលកាប់ឈើញឹកញាប់ក្នុងតំបន់ការពារ ។

# អង្គការ គ្រឹះស្ថានឧត្តមសិក្សា ម្ចាស់ជំនួយ និងវិស័យឯកជន

## សិក្ខាកាមដែលអញ្ជើញមកពី អង្គការជាតិ អង្គការអន្តរជាតិ សង្គមស៊ីវិល គ្រឹះស្ថានឧត្តមសិក្សា ម្ចាស់ជំនួយ និងវិស័យឯកជន បានធ្វើការពិភាក្សា

| | |
|---|---|
| ១-ការប្រឈមនឹងគោលនយោបាយ | • គោលនយោបាយឯកជនភាវូបនីយកម្មធនធានធម្មជាតិមានល្បឿនលឿនជាងការអនុវត្តគោលនយោបាយគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍<br>• ភាពផ្ទុយគ្នា និងត្រួតស៊ីគ្នា នៃច្បាប់ជាតិ ក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ<br>• ខ្វះក្របខ័ណ្ឌច្បាប់ អនុក្រឹត្យ ប្រកាសស្តីពីសហគមន៍តំបន់ការពារធម្មជាតិ<br>• ការសុំសិទ្ធិស្តីពីការធ្វើអាជីវកម្មព្រៃឈើ និងអនុផលព្រៃឈើមានភាពស្មុគស្មាញ<br>• ដំណើរការបង្កើតសហគមន៍ព្រៃឈើមានរយៈពេលវែង និងមានស្ថាប័នពាក់ព័ន្ធច្រើនពីថ្នាក់មូលដ្ឋាន ដល់ថ្នាក់ជាតិ<br>• បញ្ហាសុពលភាពនៃអាជ្ញាប័នមានរយៈពេលខ្លីពេក (១ឆ្នាំ)<br>• គោលការណ៍ណែនាំសម្រាប់រៀបចំសហគមន៍តំបន់ការពារធម្មជាតិ នៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ<br>• ការផ្តល់អាជ្ញាប័នអោយក្រុមហ៊ុនមានសិទ្ធិទិញឈើដែលចាប់បានដោយរដ្ឋបាលព្រៃឈើក្នុងករណីមានបទល្មើសគឺនាំឲ្យប៉ះពាល់ដល់គោលការណ៍ស្តីពីការដេញថ្លៃជាសាធារណៈ នាំឲ្យបាត់តម្លាភាព និងចំណូលថវិការដ្ឋ<br>• និយមន័យព្រៃឈើនៅក្នុងកម្មវិធីព្រៃឈើជាតិ បានរួមបញ្ចូលទាំងចំការឈើដាំ ដែលជម្រុញឲ្យមានការបាត់បង់គម្របព្រៃធម្មជាតិលឿន<br>• ច្បាប់ព្រៃឈើដែលមានបទបញ្ញត្តិពិន័យអន្តរកាល ដែលនាំឲ្យជនល្មើសរួចខ្លួនពីការចោទប្រកាន់តាមផ្លូវតុលាការព្រោះបទបញ្ញត្តិអនុញ្ញាតិឲ្យរដ្ឋបាលព្រៃឈើបញ្ចប់បទល្មើសព្រៃឈើមួយចំនួន ត្រឹមតែការពិន័យជាប្រាក់<br>• រដ្ឋាភិបាលមិនបានអនុវត្តច្បាប់មានស្រាប់ (ការសាងសង់ទំនប់វារីអគ្គីសនីនៅទន្លេសេសាន)<br>• មិនមានការបង្ហាញច្បាស់លាស់ណាមួយថាសហគមន៍អាចសហការជាមួយឯកជនបាន<br>• ផ្តោតតែការបង្កើតលិខិតបទដ្ឋានច្បាប់ តែខ្វះយន្តការអនុវត្តជាក់ស្តែងនៅមូលដ្ឋាន<br>• គោលនយោបាយពាក់ព័ន្ធនឹងដីសម្បទានសេដ្ឋកិច្ច  មិនសូវមានការគាំទ្រពីមន្ត្រីថ្នាក់ក្រោមជាតិ<br>• ការប្រគល់ដីសម្បទានដោយរាជរដ្ឋាភិបាលទៅក្រុមហ៊ុន អាចប៉ះពាល់ដល់ដីសហគមន៍<br>• សហគមន៍ព្រៃឈើនៅតំបន់ជនជាតិដើមភាគតិច មានចំនួនតិចតួចនៅក្នុងផែនការយុទ្ធសាស្ត្រ |
| ២-ការប្រឈមទាក់ទងនឹងការអនុវត្ត | • នីតិវិធីសុំអាជ្ញាប័នមានច្រើន ស្មុគស្មាញ និងប្រើរយៈពេលយូរ<br>• សហគមន៍ទាំងបីប្រភេទ កំពុងរងការគំរាមកំហែងពីសកម្មភាពដីសម្បទានសេដ្ឋកិច្ច<br>• ការបំផ្លាញព្រៃឈើសហគមន៍ ដោយភាគីរដ្ឋ (ទាហាន)ដោយគ្មានដំណោះស្រាយ<br>• ចំណេះដឹងរបស់សហគមន៍នៅមានកម្រិត<br>• ការចូលរួមមិនសូវផុសផុល និងគិតប្រយោជន៍បុគ្គល<br>• បណ្តាញសហគមន៍ព្រៃឈើ និងតំបន់ការពារធម្មជាតិ មិនទាន់ទទួលខុសត្រូវពេញលេញទាំងថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ<br>• កង្វះខាតបច្ចេកទេសក្នុងការដកហូតអនុផលព្រៃឈើដើម្បីធ្វើអាជីវកម្ម<br>• គម្រោងថវិកាមានរយៈពេលខ្លី<br>• មន្ត្រីជំនាញជលផលមិនបានអនុវត្តច្បាប់ឲ្យបានពេញលេញ ដោយសារកង្វះខាតធនធានមនុស្ស និងថវិកា<br>• ច្បាប់ និងគោលនយោបាយមិនត្រូវបានយកទៅអនុវត្ត<br>• ការដឹកជញ្ជូនវត្ថុធាតុដើមផ្តៅពីស្រុកឆ្ងាយ និងចំណាយថវិកាច្រើន<br>• ប្រធានសហគមន៍ដែលមាននិន្នាការនយោបាយ មិនត្រូវបានលើកទឹកចិត្ត |
| ៣-អនុសាសន៍ និងសំណើសកម្មភាព | • រៀបចំយន្តការច្រកចេញចូលតែមួយ<br>• ស្នើរសុំឲ្យក្រសួងកសិកម្ម( និងអាជ្ញាធរពាក់ព័ន្ធ) សម្រួលនីតិវិធី និងពន្លឿនដំណើរការបង្កើតសហមគមន៍ព្រៃឈើ<br>• កំណត់តំបន់សក្តានុពលព្រៃសហគមន៍( កំណត់ពេលវេលាជាក់លាក់ តាមជំហ៊ាននីមួយៗ)។<br>• រាល់ការអនុវត្តន៍សកម្មភាពនីមួយៗត្រូវមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ (ស្ថាប័នជំនាញ)<br>• កំណត់តំបន់គ្រប់គ្រងតំបន់ការពារធម្មជាតិ<br>• បញ្ចូលការគិតគូពីកត្តាសេដ្ឋកិច្ចក្នុងការកំណត់តំបន់សក្តានុពល ព្រៃសហគមន៍ (សម្រាប់សហគមន៍ថ្មី)<br>• គិតគូរពីការបង្កើនផលិតភាពព្រៃសហគមន៍ (សម្រាប់សហគមន៍ដែលមានស្រាប់)<br>• បង្កើនរយៈពេលកិច្ចព្រងព្រៀង |
| ៤-មេរៀនជាបទពិសោធន៍ | • ការជម្រុញឲ្យមានការកែច្នៃផលិតផលសហគមន៍( កែច្នៃត្រី អនុផលព្រៃឈើជាដើម)<br>• ការលើកទឹកចិត្តក្នុងការបង្កើតឲ្យសហគមន៍ស្វ័យគ្រប់គ្រង<br>• ការជម្រុញឲ្យសហគមន៍អនុវត្តជាសហគ្រាសដែលអាចរកកម្រៃដោយខ្លួនឯង ដោយមិនពឹងផ្អែកលើជំនួយ<br>• ក្រសួងបរិស្ថានពុំបានអនុម័តប្រកាសក្នុងការបង្កើតតំបន់ការពារធម្មជាតិទេ ប៉ុន្តែការអនុវត្តសកម្មភាពមានល្បឿនលឿនជាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានក្របខណ្ឌគ្រប់គ្រាន់ |

គ្នាយ៉ាងសកម្ម និងទទួលបានលទ្ធផលដូចមានបង្ហាញក្នុងតារាងខាងក្រោម៖

- ភាពយឺតយ៉ាវក្នុងការជម្រុញផែនការគ្រប់គ្រង
- ការសុំសិទ្ធិធ្វើអាជីវកម្មលើផល អនុផលព្រៃឈើ ផលនេសាទ មានភាពស្មុគស្មាញ
- មិនមានគោលនយោបាយ ឬច្បាប់ឲ្យសហគមន៍ធ្វើពាណិជ្ជកម្មផល និងអនុផលព្រៃឈើ
- ភាគីពាក់ព័ន្ធច្រើន (ស្ថាប័នជំនាញ អាជ្ញាធរ...) ពិបាកក្នុងការសម្របសម្រួល (ការចូលរួមកិច្ចសហប្រតិបត្តិការ)
- មិនមានផែនការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីថ្នាក់តំបន់ច្បាស់លាស់
- កិច្ចសហការរវាងក្រសួងពាក់ព័ន្ធនៅមានកម្រិត
- លទ្ធភាពក្នុងការស្វែងរកថវិកាអនុវត្តគម្រោងមានកម្រិត (ថវិកាក្នុងការអនុវត្តគម្រោងមានរយៈពេលខ្លី)
- សហគមន៍ព្រៃឈើ៖ យឺត (និយ័តកម្ម) ផែនការគ្រប់គ្រង (ការត្រួតពិនិត្យឡើងវិញ) នីតិវិធីស្មុគស្មាញ សមត្ថភាពបច្ចេកទេស ដំណើរការអនុម័តផែនការគ្រប់គ្រង
- សហគមន៍តំបន់ការពារធម្មជាតិ៖ នីតិវិធី (អ្នកអនុម័តលក្ខខន្តិកៈ) និងការរៀបចំគោលការណ៍ណែនាំស្តីពី សហគមន៍តំបន់ការពារធម្មជាតិពុំទាន់មាននៅឡើយ
- ដីសម្បទាន (ព្រៃសម្បទាន) ជាន់គ្នាជាមួយនឹង តំបន់សក្តានុពលព្រៃសហគមន៍
- នីតិវិធីក្នុងការសហការរវាងសហគមន៍ និងផ្នែកឯកជន មិនទាន់មានភាពច្បាស់លាស់
- មិនមានគោលនយោបាយច្បាស់លាស់ ដែលចែងថាសហគមន៍អាចសហការណ៍ ជាមួយផ្នែកឯកជន (ឧ. កិច្ចព្រមព្រៀងសហគមន៍ មិនបានចែងពីសិទ្ធិជាក់លាក់របស់សហគមន៍ ក្នុងការសហការរវាងសហគមន៍ និងវិស័យឯកជន)
- ការទទួលស្គាល់ផលិផលរបស់សហគមន៍ (ពីសហគមន៍ព្រៃឈើ)៖ ការបញ្ជាក់ផលិតផលចេញពីព្រៃសហគមន៍ (សហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ) ដែលនាំអោយការដឹកជញ្ជូនផលិតផលពីព្រៃសហគមន៍មានការលំបាក
- ធនធានព្រៃសហគមន៍ ពុំមានសក្តានុពលសម្រាប់ការផ្តល់ផលដល់សហគមន៍ ក្នុងការរួមចំណែកដល់លើកកម្ពស់ជីវភាពរបស់នៅរបស់សហគមន៍ (តំលៃសេដ្ឋកិច្ចពីធនធាន) ហើយ រយៈពេលកិច្ចព្រមព្រៀងខ្លី (១៥ឆ្នាំ)
- ធនធានមនុស្សរួមទាំង ចំនួនមនុស្ស និងសមត្ថភាព/ជំនាញ (ស្ថាប័នជំនាញ អាជ្ញាធរ និងអង្គការ) ក្នុងការងារសហគមន៍ នៅមានកម្រិត
- យន្តការសម្របសម្រួល និងកិច្ចសហការ រវាងអង្គការ និងអង្គការនៅមានកម្រិត
- ការអនុម័តតំបន់សហគមន៍ព្រៃឈើ មានភាពយឺតយ៉ាវ

---

- ការប្រកាន់និន្នាការនយោបាយក្នុងសហគមន៍នាំអោយប៉ះពាល់ដល់ការអភិវឌ្ឍសហគមន៍
- ម្ចាស់ជំនួយគាំទ្រលើសលុបលើផែនការនៅថ្នាក់ជាតិ តែតិចតួចបំផុតនៅថ្នាក់មូលដ្ឋាន និងការផ្តល់ជំនួយមានរយៈពេលខ្លី
- ថវិកាមិនគ្រប់គ្រាន់ក្នុងការអនុវត្ត ជំហានទី៣ នៃផែនការគ្រប់គ្រង សហគមន៍ព្រៃឈើ
- ដំណើរសហគមន៍ពឹងផ្អែកលើអង្គការ និងម្ចាស់ជំនួយ ជាហេតុធ្វើឲ្យមិនមាននិរន្តរភាព
- អាជ្ញាធរមូលដ្ឋាន មិនទាន់យល់ច្បាស់ពីដំណើរការ និងទស្សនទាននៃការបង្កើតសហគមន៍
- អាជ្ញាធរមូលដ្ឋានមិនទាន់យល់ពីសិទ្ធិ និងដែនសមត្ថកិច្ចរបស់ខ្លួន ដោយផ្អែកលើមន្ត្រីជំនាញក្នុងការបង្ក្រាបបទល្មើស
- ស្ថាប័ន និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធមិនសូវយកចិត្តទុកដាក់លើសកម្មភាពរបស់សហគមន៍
- កង្វះការសហការរវាងសហគមន៍ ស្ថាប័នជំនាញ និងអាជ្ញាធរមូលដ្ឋាន
- ការចែករំលែកព័ត៌មានរវាងសហគមន៍ និងស្ថាប័នជំនាញមិនសូវច្បាស់លាស់
- ពិបាកទំនាក់ទំនងជាមួយមន្ត្រីថ្នាក់ជាតិនៅពេលមានបទល្មើសធំៗ
- ការកំណត់តំបន់សក្តានុពល សម្រាប់សហគមន៍ព្រៃឈើ/សហគមន៍តំបន់ការពារធម្មជាតិនៅមាន៖
    - ជាន់គ្នាជាមួយសម្បទាន (ព្រៃសម្បទានសេដ្ឋកិច្ច) សហគមន៍ មិនសូវទទួលបានអាទិភាព
    - តំបន់សក្តានុពល សហគមន៍ នៅលើព្រៃរេចរឹល

---

- រដ្ឋបាលព្រៃឈើសម្របសម្រួលដំណើរការបច្ចេកទេស
- រដ្ឋបាលព្រៃឈើគួរកំណត់ពេលវេលាពិនិត្យ និងមាននីតិវិធីលើគោលការណ៍ណែនាំ
- រៀបចំគោលការណ៍ណែនាំស្តីពីសហគមន៍តំបន់ការពារធម្មជាតិ (សម្រួលដំណើរការឲ្យសាមញ្ញ និងខ្លីជាងមុន)
- បង្កើតយុទ្ធសាស្ត្រស្វែងរកថវិការយៈពេលវែង
- ស្ថាប័នជំនាញ គួរពិនិត្យលទ្ធភាពក្នុងការពង្រឹងសមត្ថភាពសហគមន៍ ឲ្យមានលទ្ធភាពរួមចំណែកអនុវត្តន៍ការងារបច្ចេកទេសមួយចំនួន ព្រមទាំងទទួលស្គាល់លទ្ធផលការងារនេះ
- ពង្រឹងសមត្ថភាពអង្គភាព និងសមាជិកសហគមន៍ព្រៃឈើ
- ពង្រឹងសមត្ថភាពមន្ត្រីអង្គការក្រៅរដ្ឋាភិបាល

---

- សហគមន៍ដែលអនុវត្តកម្មវិធីបង្កើនប្រាក់ចំណូលដោយខ្លួនឯងអាចទប់ស្កាត់បទល្មើស និងគ្រប់គ្រងធនធានបានជោគជ័យ (សហគមន៍ទេសចរណ៍ធម្មជាតិ) ជាងសហគមន៍ដែលមិនមានប្រភពចំណូល
- ការសហការគាំទ្រពីរដ្ឋាភិបាល
- សហគមន៍អាចដំណើរការក្នុងការគ្រប់គ្រងបានដោយខ្លួនឯង
- ការបង្កើតតំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើ ពិតជាជួយរួមចំណែក ក្នុងការគ្រប់គ្រងព្រៃឈើ ជីវចម្រុះ និងកាត់បន្ថយភាពក្រីក្រ។



# ជំហានបន្ទាប់ និងការប្តេជ្ញាចិត្តក្នុងការអភិវឌ្ឍសហគមន៍ព្រៃឈើនាពេលអនាគត

## រដ្ឋបាលព្រៃឈើ (សហគមន៍ព្រៃឈើ)

- រៀបចំប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ឲ្យបាន ៣២ សហគមន៍ក្នុងមួយឆ្នាំ
- ចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ឲ្យបាន ៥០ សហគមន៍ក្នុងមួយឆ្នាំ
- រៀបចំសៀវភៅគោលការណ៍ណែនាំស្តីពីការសរសេរផែនការគ្រប់គ្រងព្រៃសហគមន៍
- ពង្រឹងគណៈកម្មការសម្របសម្រួលកម្មវិធីសហគមន៍ថ្នាក់ខេត្ត តាមរយៈការបង្កើតឱ្យមានគណៈកម្មការនេះ (៥ ខេត្តក្នុងមួយឆ្នាំ)
- រៀបចំការប្រលងជ្រើសរើសសហគមន៍ល្អ ក្រោមប្រធានបទ "ការបង្កើតជីវភាពតាមរយៈសហគមន៍ព្រៃឈើ"។

## អគ្គនាយកដ្ឋាន រដ្ឋបាលការពារ និងអភិរក្សធម្មជាតិ (សហគមន៍តំបន់ការពារធម្មជាតិ)

- សម្រេចឲ្យបាននូវគោលការណ៍នែនាំស្តីពីការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ
- កំណែទម្រង់ នីតិវិធី នៃការរៀបចំសហគមន៍៖ អាណត្តិ (កិច្ចព្រមព្រៀងពី ១៥ ឆ្នាំ ទៅរយៈពេល ៣០ ឆ្នាំ)



## រដ្ឋបាលជលផល (សហគមន៍នេសាទ)

- សិក្សាពីការធ្វើវិសោធន៍កម្មអនុក្រឹត្យ ដើម្បីឲ្យសហគមន៍អាចរកប្រាក់ចំណូលពីធនធានដែលមាននៅក្នុងសហគមន៍ ដូចជាការបោះបង្គោលរបាំងចាប់ត្រី និងការនេសាទដោយឧបករណ៍សមស្របទៅតាមភូមិសាស្ត្រជាដើម
- សិក្សាពីលទ្ធភាពបង្កើតតំបន់ទេសចរធម្មជាតិ ក្រុមកែច្នៃត្រី សិប្បកម្មផ្សេងៗ ដើម្បីសហគមន៍អាចមានលទ្ធភាពរកចំណូលបាន
- បង្កើតកិច្ចប្រជុំបណ្តាញសហគមន៍ថ្នាក់ខេត្ត ដើម្បីផ្តល់ឱកាសចែករំលែកបទពិសោធន៍
- ការសម្របសម្រួល និងការគាំទ្រ តាមរយៈ ពេលវេលា និងធនធាន ពីអាជ្ញាធរ និងស្ថាប័ន
- លើកទឹកចិត្តសហគមន៍តាមរយៈបោះបង្គោលព្រំប្រទល់ និងផ្តល់មធ្យោបាយក្នុងការគ្រប់គ្រង និងទប់ស្កាត់បទល្មើសនេសាទ
- ជំរុញអនុវត្តវិធានការសហគមន៍នេសាទគ្មានបទល្មើសនេសាទ
- បន្តអនុវត្តកម្មវិធីបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពសហគមន៍ក្នុងការគ្រប់គ្រង
- ជំរុញការបង្កើត និងអភិរក្សព្រៃលិចទឹក ព្រៃកោងកាង កន្លែងអភិរក្សត្រីមេពូជ
- ជំរុញការរៀបចំឯកសារដើម្បីចុះបញ្ជីសហគមន៍នេសាទឱ្យបានរួចរាល់
- ពង្រឹងបណ្តាញដៃគូ អង្គការនៅគ្រប់ថ្នាក់ ដើម្បីគាំទ្រសកម្មភាពសហគមន៍
- ជំរុញសមាហរណកម្មផែនការគ្រប់គ្រងសហគមន៍ទៅក្នុងផែនការអភិវឌ្ឍឃុំ
- លើកទឹកចិត្តសមាជិកសហគមន៍ឱ្យបង្កើនមុខរបរបន្ថែម ដើម្បីលើកកំពស់ជីវភាព
- បន្តការងារតាមដាន និងវាយតម្លៃដំណើរការគ្រប់គ្រងសហគមន៍នេសាទ ។




## ភាគីពាក់ព័ន្ធ (អង្គការ គ្រឹះស្ថានឧត្តមសិក្សា ម្ចាស់ជំនួយ  និងវិស័យឯកជន)

- អនុវត្តឲ្យសម្រេចបានទៅតាមសូចនករដែលបានកំណត់ក្នុងផែនការសកម្មភាព
- ឆ្លើយតបឲ្យបានទាន់ពេលវេលាតាមសំណូមពររបស់សហគមន៍

## សហគមន៍

- ជានាគោរពច្បាប់នៅក្នុងសហគមន៍ទៅតាមបទដ្ឋាននានាដែលបានកំណត់
- ប្តេជ្ញារៀបចំអោយបានល្អសម្រាប់ការចុះបង្ក្រាបបទល្មើស
- ហ៊ានបញ្ចេញមតិដើម្បីការពារផលប្រយោជន៍រួម
- លះបង់ពេលវេលាដើម្បីដកស្រង់បទពិសោធន៍ និងយកមកអនុវត្ត
- សហគមន៍ប្តេជ្ញាធ្វើផែនការគ្រប់គ្រងប្រើប្រាស់ថវិកាដោយមានតម្លាភាព និងបំផុសដល់សមាជិកឱ្យមានការចូលរួម
- សហការណ៍ និងអនុវត្តអោយបានល្អ
- ប្តេជ្ញាការពារថែរក្សាដីព្រៃសហគមន៍ និងមានការទទួលខុសត្រូវខ្ពស់
- អាជ្ញាធរប្តេជ្ញាគាំទ្រ និងចូលរួមក្នុងសកម្មភាពគ្រប់គ្រងថវិកា និងការការពារដែនសហគមន៍
- ប្តេជ្ញាការពារធនធានអោយមាននិរន្តភាព និងអនុវត្តបទបញ្ជាផ្ទៃក្នុង លក្ខន្តិកៈរបស់សហគមន៍
- សាមគ្គីភាពផ្ទៃក្នុង
- ពង្រឹងការចូលរួមសហការជាមួយអាជ្ញាធរ និងសមត្ថកិច្ចដែលមានការពាក់ព័ន្ធ និងរាយការពីលទ្ធផល និងបញ្ហាលំបាក។

# ការគាំទ្ររបស់ RECOFTC នៅក្នុងផែនការសកម្មភាពសហគមន៍




លោក អេដវិន ប៉ាយ័ន អ្នកសម្របសម្រួលកម្មវិធីប្រចាំប្រទេសរបស់អង្គការ RECOFTC បានលើកឡើងនៅក្នុងបទបង្ហាញរបស់លោកថា នៅក្នុងផែនការយុទ្ធសាស្ត្រថ្មីឆ្នាំ ២០១៣-២០១៨ របស់ RECOFTC បានផ្តោតទៅ លើផ្នែកធំៗបួនមាន៖ ១) សុវត្ថិភាពសហគមន៍ព្រៃឈើ (Securing Community Forestry) ២) ការលើកម្ពស់ការប្រកបរបរចិញ្ចឹមជីវិត និងទីផ្សារ (Enhancing Livelihoods and Markets) ៣) មនុស្ស ព្រៃឈើ និងការប្រែប្រួលអាកាសធាតុ (People, Forests and Climate Change) និង ៤)ការដោះស្រាយជម្លោះក្នុងវិស័យព្រៃឈើ (Transforming Forest Conflicts)។

តាមរយៈផ្នែកធំៗទាំងបួននេះ ឆ្លុះបញ្ចាំងនូវការយកចិត្តទុកដាក់ទៅលើការគាំប្រជាជនមូលដ្ឋានក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើរបស់ពួកគេ និង ផ្តល់ការគាំទ្រដល់រដ្ឋាភិបាល អង្គការ ព្រមទាំងប្រជាជនមូលដ្ឋានក្នុងការ បង្កើត និងកែលម្អគោលនយោបាយសហគមន៍ព្រៃឈើ ច្បាប់ លក្ខខន្តិក និងស្ថាប័នជាដើម។ ការពង្រឹងសមត្ថភាពដល់ ប្រជាជនមូលដ្ឋានក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើដែលប្រកបដោយនិរន្តរភាពដើម្បីលើក កម្ពស់ការចិញ្ចឹមជីវិត និងការអភិវឌ្ឍសហគ្រាស និងភ្ជាប់ផលិផលសគមន៍ ព្រៃឈើ និងសេវាកម្ម ទៅកាន់ទីផ្សារ។

លោកក៏បានបន្ថែមទៀតថា ការពង្រឹងសមត្ថភាពរបស់ប្រជាជនមូលដ្ឋានដើម្បីឆ្លើយតបទៅនឹងការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ព្រមទាំងការពង្រឹងសមត្ថភាពភាគីពាក់ព័ន្ធរួមទាំងជនជាតិដើមភាគតិចផងដែរ។ ក្នុងការដោះស្រាយជម្លោះក្នុងវិស័យព្រៃឈើក៏ជាអាទិភាពចម្បងមួយដែល នឹងត្រូវពង្រឹងបន្ថែមទៀតក្នុងយុទ្ធសាស្ត្រថ្មីនេះ។

## Capacity Development Cycle





# ការតាំងបង្ហាញស្នាដៃ និងផលិតផលសហគមន៍

ស្នាដៃបោះពុម្ព និងផលិតផលកែច្នៃពីអនុផលព្រៃឈើ និងរូបភាពស្តីពីដំណើរការសកម្មភាពបង្កើត និងអភិវឌ្ឍសហគមន៍ព្រៃឈើ ត្រូវបានតាំងបង្ហាញរយៈពេល ០២ ថ្ងៃ ក្នុងវេទិកានេះ ដោយមានការចូលរួមពីស្ថាប័នរដ្ឋចំនួន ០២ គឺរដ្ឋបាលជលផល និងរដ្ឋបាលព្រៃឈើ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ០៤ គឺ អង្គការ RECOFTC វិទ្យាស្ថានសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលវេទិកានៃអង្គការមិនមែន រដ្ឋាភិបាលស្តីពីកម្ពុជា និងអង្គការកម្មវិធីផ្លាស់ប្តូរអនុផលព្រៃឈើ។

ការតាំងបង្ហាញស្នាដៃនេះ បានរួមចំណែកលើកកម្ពស់ការយល់ដឹងរបស់អ្នកចូលរួមពីស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានអប់រំ វិស័យឯកជន អាជ្ញាធរមូលដ្ឋាន និងសហគមន៍ ទាក់ទងនឹងសកម្មភាពការងាររបស់ស្ថាប័នទាំង ០៦ ដែលបានអនុវត្តកន្លងមក និងទស្សនទានផ្សេងៗ លើដំណើរការ និងបញ្ហាការគ្រប់គ្រងធនធានធម្មជាតិ។ លើសពីនេះ ផលិតផលកែច្នៃពីអនុផលព្រៃឈើពីសហគមន៍ ដូចជា ទឹកឃ្មុំ និងសាប៊ូ ជាដើម ក៏ត្រូវបានតាំងបង្ហាញ ដែលនេះជាការឆ្លុះបញ្ចាំងនូវសក្តានុពលនៃធនធានអនុផលព្រៃឈើនៅកម្ពុជាផងដែរ និងការលើកម្ពស់របរចិញ្ចឹមជីវិតរបស់ប្រជាសហគមន៍។



# ការចូលរួមរបស់ស្ថាប័នសារព័ត៌មាន

ស្ថាប័នសារព័ត៌មានក្នុងស្រុកមួយចំនួនបានចូលរួមយកព័ត៌មានក្នុងវេទិកានេះផងដែរដូចជា ទូរទស្សន៍ជាតិកម្ពុជា ទូរទស្សន៍បាយ័ន ទូរទស្សន៍ហង្សមាស បណ្ដាញទូរទស្សន៍កម្ពុជា (CTN) វិទ្យុផ្សាយសម្លេងអូស្ត្រាលី (ABC) ទីភ្នាក់ងារសារព័ត៌មានកម្ពុជា សារព័ត៌មានដើមអំពិល សារព័ត៌មានខ្មែរដេលី សារព័ត៌មានរស្មីកម្ពុជា និងសារព័ត៌មានភ្នំពេញប៉ុស្តិ៍ (Phnom Penh Post)។ ស្ថាប័នសារព័ត៌មានទាំងអស់បានចាក់ផ្សាយ និងចេញផ្សាយព័ត៌មានរបស់ខ្លួនស្តីពីវេទិកានេះថ្ងៃបន្ទាប់ ។

# សេចក្តីអំពាវនាវឲ្យធ្វើសកម្មភាព

ការគ្រប់គ្រងធនធានធម្មជាតិតាមបែបសហគមន៍នៅក្នុងប្រទេសកម្ពុជា មានលក្ខណៈសហគ្រប់គ្រងដែលជម្រុញ និងលើកទឹកចិត្តសហគមន៍ចូលរួមគ្រប់គ្រងធនធានឲ្យមាននិរន្តរភាព តាមរូបភាពសហគមន៍ព្រៃឈើ សហគមន៍នេសាទ និងសហគមន៍តំបន់ការពារធម្មជាតិ។ តាមរយៈបទបង្ហាញ និងការពិភាក្សានៅវេទិកាថ្នាក់តំបន់លើកទី ៣ នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃ រំលេចឲ្យឃើញនូវចំណុចប្រឈមខ្ពស់មួយរបស់ប្រទេសកម្ពុជា គឺគោលនយោបាយ និងលិខិតបទដ្ឋានច្បាប់ដែលមានភាពស្មុគស្មាញ និងនីតិវិធីរយៈពេលវែងហើយការរកឃើញនេះក៏ដូចគ្នានឹងការរកឃើញនៅក្នុងវេទិកាថ្នាក់ជាតិលើកទី ១ នេះដែរ។

បញ្ហាប្រឈមសំខាន់ៗផ្សេងទៀតក៏បានរកឃើញផងដែរនៅក្នុងវេទិកានេះ រួមមានកង្វះការសហការនិងការតភ្ជាប់បណ្តាញដែលទាមទារឲ្យមានការពង្រឹង និង បន្តកសាងទំនាក់ទំនងតាមរយៈខ្សែបណ្តោយ និងខ្សែទទឹង រវាងស្ថាប័ន និងស្ថាប័នរវាងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ រួមទាំងអង្គការមិនមែនរដ្ឋាភិបាលផងដែរ។ សមត្ថភាពមានកម្រិត ក៏នៅតែជាបញ្ហាសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ដែលទាមទារឲ្យមានការកសាងសមត្ថភាពបន្ថែមតាមរយៈការបណ្តុះបណ្តាលដើម្បីធ្វើសកម្មភាព។ កម្រិតជីវភាពរស់នៅរបស់ប្រជាសហគមន៍ក៏ជាបញ្ហាប្រឈមមួយផ្សេងទៀតដែលទាមទារឲ្យមានការប្រែក្លាយធនធាននៅក្នុងសហគមន៍ ដើម្បីទាញរកប្រាក់ចំណូលសម្រាប់ការទ្រទ្រង់ជីវភាពរស់នៅឱ្យមានភាពល្អ ប្រសើរឡើងតាមរយៈការ បង្កើតជាតំបន់អេកូទេសចរណ៍ និងការប្រមូលអនុផលព្រៃឈើជាដើម។ ប៉ុន្តែតំបន់ដែលប្រគល់អោយសហគមន៍ភាគច្រើនជាតំបន់ដែល រេចរឹលពុំមានធនធានជាសក្តានុពលសម្រាប់ការចិញ្ចឹមជីវិត ដែលជាការលំបាកក្នុងបង្កើនជីវភាពរបស់ប្រជាសហគមន៍។ ទន្ទឹមនឹងនេះ បញ្ហាការកសាងភាពជាដៃគូរវាងអ្នកពាក់ព័ន្ធទាំងអស់ (កង្វះការគាំទ្រពីអាជ្ញាធរមូលដ្ឋាន ការសម្របសម្រួល និងអនុម័តផែនការគ្រប់គ្រងសហគមន៍មានភាពយឺតយ៉ាវជាដើម) នៅតែកើតមានឡើង។ បញ្ហាប្រឈមមួយទៀត គឺការរៀបចំចងក្រងឯកសារស្តីអំពីការអនុវត្តល្អ និងបទសោធន៍គំរូក្នុងដំណើរការនៃការចងក្រងសហគមន៍ដែលប្រការនេះមានសារៈសំខាន់ជាមេរៀនសម្រាប់រៀនសូត្រ ។ បច្ចុប្បន្ន ការចែករំលែកការអនុវត្តល្អៗនៅវេទិកាផ្សេងទៀតនៅមានកម្រិតនៅឡើយ ពីព្រោះមិនមានឯកសារគ្រប់គ្រាន់។ ចំណុចប្រឈមចម្បងមួយទៀត គឺកង្វះការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើដំណើរការអភិវឌ្ឍន៍សហគមន៍ ថាតើសហគមន៍បរាជ័យ ឬទទួលបានជោគជ័យ។ ដូចនេះលក្ខណៈវិនិច្ឆ័យ ឬសូចនាករដើម្បីធ្វើការវាស់វែងគួរត្រូវបានបង្កើត។

ដើម្បីឆ្លើយតបទៅនឹងបញ្ហានានាដែលបានលើកឡើងខាងលើនេះ វេទិកានេះបានអំពាវនាវឲ្យធ្វើសកម្មភាពដូចខាងក្រោម៖

- *កែសម្រួល ឬរៀបចំនូវគោលការណ៍ណែនាំ និងក្របខ័ណ្ឌច្បាប់នានា ដូចជាគោលការណ៍ណែនាំស្តីពីការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ គោលការណ៍ណែនាំស្តីពីការរៀបចំផែនការគ្រប់គ្រង ឲ្យមានភាពងាយស្រួល ដើម្បីឆ្លើយតបនឹងតម្រូវការជាក់ស្តែងលើការអភិវឌ្ឍសហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ និងសហគមន៍នេសាទ*

- *ការគិតគូរពីទំនាក់ទំនងនៃការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ និងសហគមន៍នេសាទ អាចជួយដល់ការបង្កើននូវការចិញ្ចឹមជីវិតរបស់ប្រជាសហគមន៍ដែលបានចូលរួម ក្នុងការគ្រប់គ្រងធនធានធម្មជាតិ ដោយប្រើប្រាស់ធនធានធម្មជាតិដែលមានស្រាប់នៅក្នុងមូលដ្ឋានរបស់ខ្លួនជាចំណុចចាប់ផ្តើមក្នុងការគិតគូរដល់ការអភិវឌ្ឍន៍សហគមន៍របស់ខ្លួន*

- *ភាពជាដៃគូ និងកិច្ចសហការគឺជាតម្រូវការចាំបាច់ ដើម្បីសម្រួលដល់ដំណើរការនៃការអភិវឌ្ឍ និង គ្រប់គ្រងសហគមន៍ខាងលើដើម្បីធ្វើយ៉ាងណាអោយតួនាទីរបស់អ្នកពាក់ព័ន្ធទាំងនេះអាចជួយគាំទ្រគ្នាទៅវិញទៅមកដើម្បីសម្រួលការងារអោយកាន់តែមានប្រសិទ្ធិភាព*

- *ការបង្កើតនូវគោលការណ៍ លក្ខណៈវិនិច្ឆ័យ និងសូចនាករ ដែលអាចជួយដល់ការវាស់វែងនូវភាពជោគជ័យនៃការគ្រប់គ្រងដោយ មានការចូលរួមនេះ និងអាចធ្វើការចងក្រងនូវឯកសារសម្រាប់ជាបទពិសោធន៍ក្នុងការចែករំលែកក្នុងចំណោមអ្នកអនុវត្តទាំងឡាយ*

- *ការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងតំបន់ទេសភាព ដោយមានលក្ខណៈជាប្រព័ន្ធដោយផ្តល់អោយអ្នកភូមិ នានានូវឱកាសក្នុងការទទួលបាននូវតំបន់ព្រៃឈើដែលមានទំហំធំ ព្រោះប្រការនេះអាចដោះស្រាយបាននូវការរុករានតំបន់ដែលពុំមានការគ្រប់គ្រង និងអាចផ្តល់នូវផលប្រយោជន៍សេដ្ឋកិច្ចដល់ប្រជាសហគមន៍ជាជាងការផ្តល់តែតំបន់ព្រៃដែលរេចរឹល។ ជាពិសេសយុទ្ធសាស្ត្រនេះអាចតភ្ជាប់នូវគម្លាតនៃការគ្រប់គ្រងព្រៃសហគមន៍តំបន់ការពារព្រៃសហគមន៍និងតំបន់ផ្សេងៗទៀត ព្រមទាំងអាចតភ្ជាប់ទំនាក់ទំនងនៃការគ្រប់គ្រងជាមួយស្ថាប័នពាក់ព័ន្ធ*
- *ស្ថាប័នរដ្ឋាភិបាលសម្របសម្រួលនីតិវិធីនៃការធ្វើផែនការគ្រប់គ្រងព្រៃសហគមន៍តាមរយៈការរៀបចំគោលការណ៍ណែនាំ*
- *អង្គការក្រៅរដ្ឋាភិបាល បន្តធ្វើការជាដៃគូជាមួយរដ្ឋាភិបាល និងសហគមន៍ តាមរយៈយន្តការសម្របសម្រួលតែមួយរួមគ្នា*
- *កសាងសមត្ថភាពដល់មន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មន្ត្រីអង្គការក្រៅរដ្ឋាភិបាល*
- *ការកសាងសមត្ថភាពរបស់អាជ្ញាធរមូលដ្ឋាន និងគណៈកម្មការគ្រប់គ្រងសហគមន៍តាមរយៈការបង្កើតឲ្យមានវគ្គបណ្តុះបណ្តាលជាដើម។*

# សេចក្ដីសន្និដ្ឋាន

សរុបមក វេទិកាថ្នាក់ជាតិលើកទី១ ស្ដីពី មនុស្ស និងព្រៃឈើ ក្រោមប្រធានបទ "វិថីឆ្ពោះទៅការគ្រប់គ្រងព្រៃឈើ និងការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព" ទាំងពីរថ្ងៃត្រូវបានបញ្ចប់ប្រកបដោយភាពជោគជ័យ។ សាវតា វឌ្ឍនភាព បញ្ហាប្រឈម បទពិសោធន៍ និងផែនការ សកម្មភាពសម្រាប់អភិវឌ្ឍន៍សហគមន៍ព្រៃឈើ សហគមន៍នេសាទ និងសហគមន៍តំបន់ការពារធម្មជាតិ របស់ស្ថាប័នរដ្ឋាភិបាល គ្រឹះស្ថានឧត្តមសិក្សា វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងសហគមន៍ ត្រូវបានចែករំលែកដល់អ្នកចូលរួម ។ ចំណុចសំខាន់ៗមួយចំនួនដែលអ្នកពាក់ព័ន្ធក្នុងការងារគ្រប់គ្រងធនធានធម្មជាតិ ដែលរួមមានទាំងស្ថាប័នរដ្ឋាភិបាល អង្គការជាតិ អង្គការអន្តរជាតិ អ្នកផ្ដល់ជំនួយ អាជ្ញាធរមូលដ្ឋាន វិស័យឯកជន ព្រមទាំងប្រជាសហគមន៍ ត្រូវបានលើកយកមកពិភាក្សាយ៉ាងផុសផុល។

លោក អ៊ុក ណារ៉ាន់ អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន ដែលបានចូលរួមជាអធិបតីក្នុងកម្មវិធីបិទវេទិការនេះបានចាត់ទុកវេទិកានេះជាសក្ខីភាពបង្ហាញនូវកិច្ចសហការដ៏មានសារៈសំខាន់មួយ ដែលអាចជាចលករក្នុងការរួមចំណែក បង្កើននូវប្រសិទ្ធភាពនៃការអភិវឌ្ឍន៍សហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍នេសាទដែលកំពុងតែអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះវេទិកាបានផ្ដល់ឱកាសឲ្យស្ថាប័នរដ្ឋ និងអ្នកពាក់ព័ន្ធមកជជែកពិភាក្សាគ្នា ដើម្បីស្វែងរក ការផ្ដួចផ្ដើមគំនិតថ្មីក្នុងការអភិវឌ្ឍសហគមន៍ និងការគ្រប់គ្រងធនធានធម្មជាតិ ជាពិសេសឆ្លើយតបដល់ការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា។ ការគ្រប់គ្រងធនធម្មជាតិមានភាពស្មុគស្មាញ មានភាគីពាក់ព័ន្ធច្រើន និងជួបបញ្ហាប្រឈមដូចជាសំពាធផ្នែកគោលនយោបាយ ក្របខ័ណ្ឌច្បាប់ ការងារអភិបាលកិច្ច និងវិមជ្ឈការ គម្រោងវិនិយោគ យន្តការនៃការដោះស្រាយទំនាស់ ការគ្រប់គ្រងព័ត៌មាន និងជាពិសេស បញ្ហាជីវភាពរស់នៅរបស់ប្រជាសហគមន៍ដែលពឹងអាស្រ័យលើធនធានធម្មជាតិ។ ដូច្នេះការដោះស្រាយនូវភាពប្រឈមនានា គឺជាការងារមួយដែលទាមទារឲ្យមាននូវការប្ដេជ្ញាចិត្ត និងកិច្ចខិតខំប្រឹងប្រែងទាំងកម្លាំងកាយ និងកម្លាំងចិត្តដើម្បីប្រែក្លាយភាពប្រឈមឲ្យទៅជាកាលានុវត្តភាពដែលអាចអនុវត្តបានក្នុងចំណោមអ្នកពាក់ព័ន្ធទាំងអស់។

លោកសង្ឃឹម និងជឿជាក់ថា អ្នកចូលរួមក្នុងវេទិកាជាតិនេះទាំងអស់នឹងយកសកម្មភាពទាំងអស់នេះទៅអនុវត្តនៅក្នុងស្ថាប័ន និងសហគមន៍របស់ខ្លួន និងអាចសហការណ៍ល្អជាមួយគ្នាដើម្បីសម្រេចបានលទ្ធផល ជាមួយគ្នានេះដែរលោកសង្ឃឹមថា លទ្ធផល និងបទពិសោធន៍ដែលចេញពីការអនុវត្តន៍សកម្មភាពទាំងអស់នេះនឹងត្រូវយកមកចែករំលែក និងឆ្លុះបញ្ចាំងជាថ្មីម្ដងទៀតនៅក្នុងវេទិកាជាតិលើកទី ២ ស្ដីពីមនុស្ស និងព្រៃឈើ នាពេលអនាគត។

អ្នកចូលរួមបានវាយតម្លៃខ្ពស់ទៅលើវេទិកាដោយបានលើកឡើងក្នុងកម្រងសំណួរវាយតម្លៃថា ពួកគាត់ទទួលបានចំណេះដឹងកាន់តែប្រសើរឡើងទាក់ទងទៅនឹងស្ថានភាពបច្ចុប្បន្នរបស់សហគមន៍ ដោយរួមមានទាំងលក្ខខណ្ឌគោលនយោបាយ ច្បាប់ និងការអនុវត្តកម្មវិធីផ្សេងៗក្នុងសហគមន៍ ព្រមទាំងតួនាទីរបស់ភាគីពាក់ព័ន្ធនានាក្នុងការជួយគាំទ្រដល់សហគមន៍ទាំងបី ជាពិសេសការយល់ដឹងអំពីការគ្រប់គ្រងសហគមន៍ប្រកបដោយនិរន្តរភាព ( សិទ្ធិកាន់កាប់ កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រង ) និងលើកការកម្ពស់របរចិញ្ចឹមជីវិតរបស់ប្រជាសហគមន៍។ លើសពីនេះទៀតអ្នកចូលរួមក៏បានលើកឡើងថា ពួកគេបានដឹងពីសកម្មភាពជាអាទិភាពដែលភាគីពាក់ព័ន្ធទាំងអស់នឹងត្រូវចំបាច់អនុវត្តនៅក្នុង រយៈពេល ៥ ឆ្នាំខាងមុខ ។

2/27/2014

ABC Radio Australia

# រដ្ឋាភិបាលរៀបចំវេទិកាជាតិលើកទី១ស្តីពី មនុស្សនិងព្រៃឈើ

ដាក់បញ្ចូលពេល 25 February 2014, 17:18 AEST

**នៅព្រឹកថ្ងៃទី២៥ ខែកុម្ភៈនេះ រដ្ឋបាលព្រៃឈើបានសហការជាមួយមជ្ឈមណ្ឌលសម្រាប់មនុស្សនិងព្រៃឈើ បានរៀបចំវេទិកាថ្នាក់ជាតិលើកទី១ ស្តីពី មនុស្ស និងព្រៃឈើ ដើម្បីជំរុញឲ្យមានការគ្រប់គ្រងព្រៃឈើ សម្រាប់ការចិញ្ចឹមជីវិតមនុស្សប្រកបដោយនិរន្តរភាព។**



លោក ជា សំអាង អនុប្រធានរដ្ឋបាលព្រៃឈើ ជំរុញឲ្យសហគមន៍ ព្រៃឈើដើរតួនាទីការពារការបំផ្លាញព្រៃឈើ។ រូបភាពដោយសរ សុវណ្ណារ៉ា (Credit: ABC Licensed)

មន្ត្រីរដ្ឋបាលព្រៃឈើបានធ្វើការអំពាវនាវ ឲ្យមានការចូលរួមគ្រប់គ្រងព្រៃឈើ នៅក្នុងសហគមន៍ ដើម្បីឲ្យព្រៃឈើ អាចផ្តល់ប្រយោជន៍សម្រាប់ជីវិតមនុស្សដោយនិរន្តរភាព។

លោក ជា សំអាង អនុប្រធានរដ្ឋបាលព្រៃឈើបានធ្វើការប្រកាសនៅក្នុងវេទិកាជាតិព្រៃឈើ និងមនុស្ស តាមរយៈការជំរុញលើកទឹកចិត្តឲ្យសហគមន៍បង្កើនការអនុវត្តច្បាប់ដើម្បីការពារព្រៃឈើឲ្យបានគង់វង្ស ដែលប្រជាពលរដ្ឋអាចទាញយកផលមកចិញ្ចឹមជីវិត។

(សំឡេងលោក ជា សំអាង)

លោកបានបញ្ជាក់ទៀតថា រដ្ឋាភិបាលបានផ្តល់តួនាទី ដល់សហគមន៍ព្រៃឈើ នៅក្នុងការការពារព្រៃឈើ តាមរយៈការបង្កើតបានសហគមន៍ព្រៃឈើ ចំនួន៤៥៧កន្លែងគ្របដណ្តប់ លើផ្ទៃដីព្រៃចំនួនជាង ៤០០ពាន់ហិកតា នៅក្នុង២១ខេត្ត។

ក្រុមតំណាងតំបន់ភ្នំ បានឲ្យដឹងថា ព្រៃឈើបានផ្តល់អនុផលជាច្រើនដល់ប្រជាពលរដ្ឋ ដើម្បីចិញ្ចឹមជីវិត ដូចជា ផ្តល់ ផ្កា ទឹកឃ្មុំ ផ្សិត រុក្ខជាតិឱសថ ជាដើម។ ៨០ភាគរយ នៃប្រជាពលរដ្ឋ តំបន់ភ្នំបានទទួលប្រយោជន៍ពីអនុផលទាំងនេះ។

លោក ឈឺ ឈន ប្រធានសហគមន៍តំបន់ការពារព្រៃធម្មជាតិ ជីមកបឹងព្រៃ ខេត្តព្រះវិហារ បានមកចូលនៅក្នុងវេទិកាព្រៃឈើនេះ។ លោកបានបញ្ជាក់ថា សហគមន៍បានជួយការពារព្រៃធម្មជាតិ។

(សំឡេងលោក ឈឺ ឈន)

តែទោះជាយ៉ាងណាក្តី ព្រៃឈើប្រទេសកម្ពុជាបាននិងកំពុងរងនូវសកម្មភាពកាប់ដោយខុសច្បាប់ ជាពិសេស ព្រៃឈើនៅក្រៅសហគមន៍។

លោក ជា សំអាង អនុប្រធានរដ្ឋបាលព្រៃឈើបានធ្វើការជំរុញឲ្យសហគមន៍ជួយទប់ទល់ចំពោះសកម្មភាពបំផ្លាញព្រៃឈើ។

(សំឡេងលោក ជា សំអាង)

មន្ត្រីបរិស្ថានបានឲ្យដឹងថា ការអភិរក្សព្រៃឈើបានជាផលប្រយោជន៍សេដ្ឋកិច្ច និងបរិស្ថាន។ ផលប្រយោជន៍បរិស្ថាន គឺបានជួយទប់ទល់នឹងការប្រែប្រួលអាកាសធាតុ។

---

## ជា សំអាង៖ ប្រជាពលរដ្ឋ មានសិទ្ធិ ក្នុងការទប់ស្កាត់ បទល្មើសឧក្រិដ្ឋ

Tuesday, 25 February 2014 11:56 ដោយ ៖ ដើមអម្ពិល (DAP) ID- 014

ភ្នំពេញ៖ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៤នេះ លោកបណ្ឌិត ជា សំអាង អនុប្រធានរដ្ឋបាលព្រៃឈើ បានអះអាងឲ្យដឹងថា ប្រជាពលរដ្ឋ មានសិទ្ធិក្នុងការទប់ស្កាត់បទល្មើសឧក្រិដ្ឋ។

ការអះអាងបែបនេះ ធ្វើឡើងនៅក្នុងកម្មវិធីវេទិកាស្តីពី មនុស្ស និងព្រៃឈើ ក្រោមប្រធានបទ វិធីឆ្ពោះទៅការគ្រប់គ្រងព្រៃឈើ និងការចិញ្ចឹមជីវិត ប្រកបដោយនិរន្តភាព នៅក្នុងសណ្ឋាគារភ្នំពេញ។

លោកបណ្ឌិត ជា សំអាង អនុប្រធានរដ្ឋបាលព្រៃឈើ បានមានប្រសាសន៍ថា "បើយើងមើល ទៅលើក្រមព្រហ្មទណ្ឌ ប្រជាពលរដ្ឋក៏មានសិទ្ធិ ក្នុងការចូលរួមបង្ក្រាបបទល្មើស ដែលយើងហៅថា បទឧក្រិដ្ឋ។ ប៉ុន្តែ ការចូលរួមនេះ ត្រូវអនុវត្តទៅ តាមគោលការណ៍ ដែលចាំបាច់ចូលរួមទប់ស្កាត់ ហើយបញ្ជូននូវភស្តុតាងទាំងនោះ និងបទល្មើសទាំងនោះទៅឲ្យសមត្ថកិច្ច"។

លោកបណ្ឌិត បានមានប្រសាសន៍បន្ថែមថា រយៈពេល២០ឆ្នាំមកនេះ រាជរដ្ឋាភិបាល បានរៀបចំគោលនយោបាយ, ច្បាប់, ក្រឹត្យច្បាប់, អនុក្រឹត្យ, ប្រកាស និងគោលការណ៍ណែនាំផ្សេងៗជាច្រើន មានគោលនយោបាយវិស័យព្រៃឈើ, ច្បាប់ស្តីពី ព្រៃឈើ, ច្បាប់ស្តីពី ជលផល,ច្បាប់ស្តីពី តំបន់ការពារធម្មជាតិ, អនុក្រឹត្យស្តីពី ការគ្រប់គ្រងសហគមន៍ព្រៃឈើ, អនុក្រឹត្យស្តីពី ការគ្រប់គ្រងសហគមន៍នេសាទ, ប្រកាសស្តីពី

---

## មជ្ឈមណ្ឌល សម្រាប់មនុស្ស និងព្រៃឈើ បើកវេទិកា គ្រប់គ្រងព្រៃឈើ និងការចិញ្ចឹមជីវិត

Tuesday, 25 February 2014 09:48 ដោយ: ដើមអម្ពិល (DAP)-ID: 011

ភ្នំពេញ៖ មជ្ឈមណ្ឌល សម្រាប់មនុស្ស និងព្រៃឈើ (RECOFTC) នៅថ្ងៃទី២៥-២៦ ខែកុម្ភៈ ឆ្នាំ២០១៤ នាសណ្ឋាគារភ្នំពេញ បើកវេទិកា ស្តីពីមនុស្ស និងព្រៃឈើ ក្រោមប្រធានបទ វិធីឆ្ពោះទៅការគ្រប់គ្រងព្រៃ ឈើ និងការចិញ្ចឹមជីវិត ប្រកដោយ និរន្តរភាព ។

THE CENTER FOR PEOPLE AND FORESTS

RECOFTC's mission is to enhance capacities for stronger rights, improved governance and fairer benefits for local people in sustainable forested landscapes in the Asia and the Pacific region.

RECOFTC holds a unique and important place in the world of forestry. It is the only international not-for-profit organization that specializes in capacity development for community forestry. RECOFTC engages in strategic networks and effective partnerships with governments, nongovernmental organizations, civil society, the private sector, local people and research and educational institutes throughout the Asia-Pacific region and beyond. With over 25 years of international experience and a dynamic approach to capacity development – involving research and analysis, demonstration sites and training products – RECOFTC delivers innovative solutions for people and forests.

RECOFTC – The Center for People and Forests
P.O. Box 1111
Kasetsart Post Office
Bangkok 10903, Thailand
Tel (66-2) 940-5700
Fax (66-2) 561-4880
info@recoftc.org
www.recoftc.org

Printed on recycled paper

Norad

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development and Cooperation SDC

SWEDEN